ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

## អ្នកព្រះភិរម្យភាសា អ៊ូ ហៅ ង៉ុយ

# ច្បាប់ក្រមង៉ុយ

❶ បណ្តាំក្រមង៉ុយ

❷ សេចក្តីរំលឹកដាស់តឿន

❸ ច្បាប់កេរកាលថ្មី

❹ ច្បាប់ល្បើកថ្មី

❺ ពាក្យកាព្យប្រដៅជនប្រុស-ស្រី

រៀបចំចងក្រងដោយ

កម្មវិធីស្រាវជ្រាវ និងស្វែងយល់អំពីច្បាប់

www.lorkremlaw.wordpress.com

រាជធានីភ្នំពេញ-២០១៤

# បណ្ដាំក្រមង៉ុយ

នេះបទព្រហ្មប្រាជ្ញប្រែ ប្រាយប្រាប់ខ្មែរទាំងប្រុសស្រី
ឲ្យប្រិតប្រុងស្មារតី គួរគប្បីឲ្យអុស្សាហ៍។
កុំខ្ជិលកុំល្ងង់ពេក ខំរៀនលេខរៀនអក្ខរា
រៀនគ្រប់សព្វធម៌អាថ៌ ប្រាជ្ញាផ្សំនឹងគំនិត ។
កំណើតកើតជាមនុស្ស មើលឲ្យផុះទោះឆ្ងាយជិត
ចេះស្មាត់ប្រាកដពិត គិតការអ្វីបានគ្រប់យ៉ាង។
មនុស្សល្ងង់មិនផ្អើលភ្ញាក់ ដូចក្អែកខ្វាក់ទាំងសងខាង
មានរូបគ្មានអ្វីអាង សាងបាបថោកកើតមកខ្វៅ។
ពូជមនុស្សទោះខ្ពស់ទាប កាត់តាមភាពត្រកូលផៅ
អាក្រក់ល្អសខ្មៅ កាត់កូនចៅដូចដូនតា។
ពូជល្ងង់មិនបានបួស ទុកជាទោសនឹងសាសនា
អ្នកបួសចេះធម៌អាថ៌ កូនសិក្សាខំរៀនសូត្រ ។
ពូជខ្វៅមិនសូវប្រាជ្ញ ពូជកោងកាចមិនសូវស្លូត
ពូជត្រង់ៗរហូត ពូជករភូតមិនផុតផៅ ។
ឪពុកម្ដាយស្លូតត្រង់ ចិត្តមិនចង់ឲ្យកូនខ្វៅ
ដេរវាយស្ដីប្រដៅ ឲ្យកូនចៅបានចេះដឹង។
ឪពុកគ្មានតំរិះ ឃើញកូនចេះមិនដែលខឹង

ឃើញកូនខំប្រិតប្រឹង ឪពុកដឹងតែងត្រេកអរ។
ដាស់តឿនកើនរំលឹក ដេរល្ងាចព្រឹកខ្វាចកូនក្រ
ចង់ឲ្យតែកូនល្អ លោមអង្វរឲ្យកូនខំ។
កូនកាចបំពេញទុក្ខ ម្ដាយឪពុកមានបារម្ភ
កូនស្លូតដឹងគួរសម មេបាថ្កុំថ្កើងកេរ្តិ៍ឈ្មោះ។
ឪពុកម្ដាយក្សត់ខ្សោយ កុំបណ្ដោយឲ្យអាប់យស
ខំរៀនឲ្យបានខ្ពស់ គ្រាន់សង្គ្រោះដល់មេបា។
អ្នកល្ងង់ហេតុពីខ្ជិល ឥតមន្ទិលរឿងធម៌អាថិ
គួរកូនចៅសិក្សា រៀនអក្ខរាទាំងប្រុសស្រី។
កាលអង្គព្រះសាស្ដា មានថេរាមានថេរី
ភិក្ខុភិក្ខុនី ធម៌បាលីចេះចាំស្ទាត់។
លោកសង្ឃខ្វះចេះស្ទើរ ចេះភ្លើៗធ្វើឲ្យភ្លាត់
ព្រះអង្គទ្រង់សន្មត សិក្ខាបទដល់ឥឡូវ ។
ទំលាប់ទំនៀមខ្មែរ ខំធ្វើស្រែចង់បានស្រូវ
អ្នករៀនច្បាប់ខុសត្រូវ ទុកជាផ្លូវភ្លឺប្រាជ្ញា។
ស្រុកសៀមលាវបារាំង ចេះតតាំងពីដូនតា
ចេះលេខចេះអក្ខរា សរសេរចារទាំងប្រុសស្រី។
ជាតិខ្មែរមិនចេះខ្មាស នាំពីចាស់គំនិតខ្ចី
ល្ងង់ដប់ចេះពីរបី ចេះដួញក្ដីមិនចេះច្បាប់។

មិនចេះលេខអក្សរ មុខមាត់ល្អប្រាជ្ញាអាប់
ឈ្មោះខ្លួនភ្នែកខ្លួនស្រាប់ គេសូត្រប្រាប់ទើបបានដឹង។
ភ្នែកជាភ្នឺក្រលែត ល្ងង់ព្រោះហេតុមិនខំប្រឹង
កើតទាស់មានចិត្តខឹង ពឹងរកគេសរសេរឲ្យ។
មនុស្សក្រហេតុពីខ្ជិល មិនរមិលមើលមុខក្រោយ
ម្យ៉ាងខ្សត់ពីព្រោះខ្សោយ ញឹងខាងឲ្យរង្វើលរក ។
ម្យ៉ាងក្រពីព្រោះល្ងង់ ដួញលិចលង់មិនលែលក
ទិញថ្លៃទៅលក់ថោក ចេះតែយកគិតមិនយល់ ។
អ្នកមានៗគំនិត ដេកដើរគិតកើតរវល់
ប្រាជ្ញាជាឫគល់ កើតអំពល់អំពីទ្រព្យ។
អ្នកល្ងង់និងអ្នកចេះ បើនឹងរិះរាយរៀបរាប់
អ្នកចេះប្រសើរគាប់ ល្ងង់ឥតភ័ព្វអាប់រាសី។
មានរូបមានជីវិត មិនចេះគិតចង់ដឹងអ្វី
រូបប្រុសរិកដូចស្រី នឹងហ៊ានស្ដីគ្មានគេស្ដាប់។
ល្ងង់ម្យ៉ាងមានអំណាច ល្ងង់កោងកាចអាងចាក់កាប់
ឆាប់ខឹងមិនដឹងច្បាប់ កាលណាស្លាប់គេត្រេកអរ។
អ្នកចេះតំរិះដល់ អ្នកល្ងង់ធ្ងល់មិនសល់ក្រ
ចេះល្អតចិត្តជាល្អ សួយអាករចូលមិនខ្វះ។
ចេះម្យ៉ាងមានអំណាច អ្នកខ្មៅខ្វាចឱនសំពះ

គេខុសដេរដៀលត្មេះ    អ្នកខ្មៅខ្វះគេលបខឹង។
ប្រាជ្ញម្យ៉ាងចេះសព្វសុស    ប្រព្រឹត្តខុសនោះមិនដឹង
មិនគិតពិនិត្យថ្លឹង    ប្រាជ្ញប្រិតប្រឹងប្រដៅគេ។
កូនចៅទោះធំតូច    ខុសខិលខូចខឹងវាយដេរ
មារយាទខ្លួនខុសគេ    មិនគ្មាន់គ្នេរកិរិយាឯង ។
កូនចៅទាំងស្រីប្រុស    ការត្រូវខុសគួរគិតក្រែង
គិតគ្រប់សព្វកន្ទែង    តែងនឹងមានរាល់រូបកាយ ។
ភ្នែកបើកភ្លឺមានពិត    មើលឃើញជិតៗរៀងអាយ
ភ្នែកធ្មេចមើលឃើញឆ្ងាយ    សព្វសុសសាយមិនសេសសល់។
រៀនរកស៊ីលក់ទិញ    ខាតចំណេញគិតឲ្យដល់
ឲ្យដឹងការកិច្ចកល    ទើបកើតផលប្រយោជន៍ខ្លួន។
ឲ្យរៀនលេខនព្វន្ត    បូកហាគុណឲ្យមាំមួន
ដីសនិងក្តារធ្នួន    ក្រែងចិនយួនបំបាត់បាន។
ជញ្ជីងភ្នែកមានល្បាក់    មើលឲ្យជាក់កុំប្រមាណ
ក្រែងខុសខាតមិនខាន    ធ្លាប់រាប់អានកុំទុកចិត្ត។
ភ្នែកមនុស្សធំរលីង    ភ្នែកជញ្ជីងគេចុចល្អិត
អ្នកល្អថ្លឹងប្រឹងប្រឹត    ព្រោះអាណិតខ្មែរល្ងង់ខ្លៅ ។
ចិនមានពីដូរលក់    ស្រូវកន្ទក់កន្ទាំងតៅ
របស់ទោះធ្វិនធៅ    សំពត់អាវខោខ្មៅស។

ខ្មែរអាងស្រូវក្នុងដោក ដូរថ្ងៃថោកអាក្រក់ល្អ
អស់ស្រូវទៅជាក្រ អង្វរចិនជឿស្រូវឯង ។
ធ្វើស្រែនឿយហត់ណាស់ ចិននៅផ្ទះដេកចំខែង
ផ្ទះចិនពីរបីល្វែង មានកន្ទ្វែងជង្រុកស្រូវ។
ជាតិខ្មែរឥតគំនិត ស៊ីមិនគិតមើលខុសត្រូវ
ជឿចិនពល់រដូវ កេរ្តិ៍ម៉ែឪចិនអូសអស់ ។
ចិនមកពីស្រុកនាយ មានសំពាយជារបស់
មិនទាន់បេះខ្មែរសោះ គ្មានកេរកោះស្រែចំការ ។
កែវកចង្ក្រានឆ្នាំង ផ្សំកំលាំងនិងប្រាជ្ញា
អំរែកជិះលើស្មា មានម្ជុស្វាជាដើមទុន។
ទំនិញមានគ្រប់មុខ ផ្លាល់ផ្ទេរទុកដាក់ដោយធុន
ចិនរែកមិនដែលពុន ស្រូវជោរជន់ពេញជង្រុក។
ឈប់រែកដេកអង្គុយ រាប់កាក់លុយប្រមូលទុក
ឪទិនស្រាពីមុខ ទុកជាធ្នាក់ទាក់កខ្មែរ ។
ចិនច្រើនខ្នាំងចិត្តខ្មៅ កន្ត្រាំងតៅធ្វើជាស្រែ
គ្មានត្បាល់គ្មានអង្រែ អង្គរខ្មែរចូលបាវចិន ។
ជាតិខ្មែរច្រើនឥតខ្នាស ស្រេកស្រាណាស់ផឹកជឿសិន
គំនិតគិតមិនធ្លិន ផឹកបង្ហិនតែទ្រព្យឯង ។
កំណើតអ្នកផឹកស្រា បែកប្រាជ្ញាច្រើនកន្ទ្វែង

អ្នកម្យ៉ាងបែកខាងល្បែង មិនគិតក្រែងខ្លាចខ្លួនក្រ ។
អាម្យ៉ាងបែកលួចឆក់ មារយាទអាក្រក់មិនបានល្អ
ផឹកចោលការរបរ ផឹកល្មើម៉ានចិនមិនគិត ។
ថាចិនមិនចេះកាញ់ ប្រាប់សំលាញ់ពួកម៉ាកមិត្ត
គួកនទោះឆ្ងាយជិត រឹតប្រមូលលុយឲ្យចិន ។
ត្រូវស្រោចង់ស៊ីឆ្ងាញ់ ជុំធាខ្លាញ់បក់ធ្លលក្លិន
ឃើញបាយសម្ល៉ឹន ផ្កាប់ចិត្តចិនយកបាយស៊ី។
ផឹកទឹកបោយត្រលោក មារយាទទាបថោករិកសៀធី
ចិនប្រើសែងរែកលី ស៊ីញយៗចិនមើលងាយ ។
ជាតិចិនកំណាញ់ស្វិត នឹកក្នុងចិត្តមិននិយាយ
មារយាទខ្មែរច្រើនរាយមាយ រលាយទ្រព្យអត់ខ្លួន។
ស៊ីឆ្ងាញ់ឆ្អែតស្កប់ស្កល់ ទាបថោកដល់ប្រពន្ធកូន
អាប់យសទាំងបងប្អូន ដល់តាដូនពូជពង្សខ្មែរ។
ជាតិចិនសុទ្ធសឹងស មានទ័លក្រខ្សត់ខ្លះដែរ
ស៊ីផឹកស្និទ្ធតាមសែ តមបាយខ្មែរមិនស៊ីសោះ ។
មានផ្ទះមានដំណាំ កាប់ដីដាំដោយកៀនកោះ
ដំឡូងត្រាវចេកម្នាស់ ស៊ីមិនអស់ទុកលក់ដូរ ។
ខ្មែរច្រើនខ្ជិលប្រមឹក កែងកោងរិកអួតអម្បូរ
ខ្វះលុយអង្គុយថ្ងូរ កើបបង្ហូរស្រូវជម្រុក ។

កូនអើយរឿងដំណាំ គួរតែដាំឲ្យគ្រប់មុខ
ដីកេរម្ដាយឪពុក មិនត្រូវទុកចោលទំនេរ ។
រាជការរាស់មានថ្ងៃ ផ្ចិតមេដៃផ្ដាច់ជាកេរ
មិនរាស់លេងទទេ ឆេះយកពន្ធរាល់ឆ្នាំ ។
ដូងស្វាយអំពៅចេក កុំខ្ជិលពេកដេកប្រចាំ
ម្ទេសស្វាម្រេចខ្ទឹមថ្នាំ ត្រូវតែដាំកុំឲ្យខ្វះ។
ទេសឯកសំពត់ស ដីវាលល្អដាំកប្បាស
កុំខ្ជិលតាមចាស់ៗ មនុស្សនឿយណាស់មិនដែលក្រ។
បន្លែដាំគ្រប់មុខ យកគ្រាប់ទុកដាំបន្ត
ចាក់ដីជាតិល្អៗ បង្ហូរស្រូវពេលល្ងាចព្រឹក។
ម្ទេសស្វាថ្នាំខ្ទឹមម្រេច លួតលាស់លេចពីស្រោចទឹក
បានផលផ្លែរីស្ទឹក កុំធ្វើងរឹករាក្រខ្ជួន។
ត្រីងៀតផ្អកប្រហុក ខ្មែរគ្រប់ស្រុកទិញដូរយួន
អំបិលធូបក្រមួន ពីតាដូនតែងដូរទិញ។
ដូរទុកដាក់ដំកល់ ស៊ីឲ្យដល់ខួបខែវិញ
ឲ្យបរិបូរពោរពេញ ខាតចំណេញកុំទិញតិច។
អំបិលទិញមួយចុង ប្រកពេញអុងអាងខាងលិច
កុំទិញក្ដោបខ្ចប់វេច អស់រំពេចគេចទិញទៀត។
អំបិលមួយស្រូវបី រាល់នឹងល្អីទូលកណ្ដៀត

ខ្លួនក្រត្រដរវេធ្មៀត មារយាទយ៉ាងហ្នឹងកុំប្រព្រឹត្ត។
កូនចៅទាំងប្រុសស្រី គួរគប្បីប្រុងគំនិត
ចិញ្ចឹមជន្មជីវិត គិតឲ្យវែងកុំគិតខ្លី។
ទំនេរល្ហែធ្វើការ សូត្រធម៌អាថិទាំងប្រុសស្រី
ឲ្យត្រឹមត្រូវបាលី ដូចស្រដីខាងដើមស្រាប់ ។
ពល់រូបទាំងប្រុសស្រី កាលចេះស្ដីព្រោះចេះស្ដាប់
ម៉ែឪតំរូវប្រាប់ កូនចៅត្រាប់តាមដូនតា។
ចាស់ម្យ៉ាងសាងសីលទាន មិនបំពានខុសពុទ្ធដិកា
កូនកាត់តាមមេបា មិនទៅណាឆ្ងាយពីផ្លូវ។
ចាស់ម្យ៉ាងសាងផលកម្ម ស្អប់សីលប្រាំដូចសត្រូវ
កូនកាត់តាមម៉ែឪ អាស្រូវកាសវិនាសខ្លួន ។
មិនជឿមគ្គជឿផល ធ្លាក់ទៅដល់អបាយបួន
កងកម្មចាំគំគួន គេចវេះពួនមិនកំបាំង ។
ព្រះអង្គមានពុទ្ធដីកា ប្រៀបឧមាជាទីតាំង
ដូចគេមានកំលាំង សំរាំងទុកទឹមរទេះ ។
នឹងបរផ្លូវវៀចត្រង់ រឹនឹងចង់បរគេចវេះ
កង់វិលមិនរបេះ ជិះដើងគេមិនឃ្វាតឃ្វា។
ពល់រូបទាំងតូចធំ ចូលរូងភ្នំរូងគុហា
យកថ្មផ្ទាំងរាំងទ្វារ កម្មវេរាតោងតាមបាន ។

កងសីលមានអង្គប្រាំ វេរាកម្មជិតដោយដាន
នរកប្រេតតិរច្ឆាន ខានឃាត់ខាំងរាំងមគ្គផល ។
គួរខំសាងសីលទាន យកនិព្វានជាត្រើយថ្កល់
យូរឆាប់គង់តែដល់ កុសលជួយចាកសង្សារ ។
កូនចៅរិះរេគិត មើលគំនិតចិត្តដូនតា
ប្រព្រឹត្តខុសសាសនា គេចកិរិយាកុំធ្វើត្រាប់ ។
មើលចាស់ណាត្រឹមត្រូវ ចុះក្នុងផ្លូវកន្ទងច្បាប់
ចាស់ស្តីគប្បីស្តាប់ ប្រិតព្រៀងប្រាប់ឲ្យប្រុងចាំ។
គោរពគុណទាំងបី សូត្របាលីតាមចំណាំ
រក្សាអង្គសីលប្រាំ កម្មវេរាតាមមិនទាន់ ។
សាសនានៅវែងឆ្ងាយ កន្ទងថ្វាយជាងពីរពាន់
សព្វថ្ងៃលៃគ្នេគ្នាន់ មិនទាន់គ្រប់ជាងប្រាំរយ។
ឥឡូវចិតប្រាំបី នៅម្ភៃមួយខាងក្រោយ
កូនចៅកុំបណ្តោយ ឲ្យលិចលង់ក្នុងសង្សារ។
មានពាក្យចាស់ដំណាល ថាកណ្តាលព្រះសាសនា
ទំនាយក្បួនតំរា ថានឹងរៀវហើយរីកវិញ ។
ហេតុនេះអស់កូនចៅ ទោះល្ងង់ខ្លៅយ៉ាងណាមិញ
ខំអុស្សាហ៍ទន្ទេញ បំពេញពាក្យពុទ្ធទំនាយ។
តំណពីថ្ងៃនេះ រៀនតំរិះកុំវាយមាយ

កូនណាមិនស្វាធ្យាយ មិនរលាយរលត់ទុក្ខ។
ដល់សាសនាគ្រប់គ្រាន់ ជួបប្រាំពាន់ទៅខាងមុខ
ទំនាយរាយទំនុក ថាឪពុកម្ដាយស្អប់កូន។
ថាកើតអន្តរកប្ប គុំសម្ងាប់គ្នាបងប្អូន
មិនដឹងតាដឹងដូន សូន្យសីលទានមិនមានសល់។
គួរគិតកុំសាងកម្ម កាន់សីលប្រាំចាំដំកល់
ខំសាងមគ្គសាងផល នឹងបានដល់ឋានសាន្តសុខ។
នឹងរួចពីកាប់ចាក់ មិនបានធ្លាក់ទៅនរក
ព្រះសិរអារ្យត្រាស់ខាងមុខ រាសាយទុក្ខសោករាល់ថ្ងៃ។
នេះហៅច្បាប់បណ្ដាំ ថាពាក្យប្រាំៗមួយផ្នូន
បទព្រហ្មគ្រប់ឃ្លាបួន ជូនថែងចប់ម្ល៉េះហើយហោង។

# សេចក្តីរំលឹកដាស់តឿន

អ្នកគិរម្យភាសាអ៊ូ លើកដៃទាំងគូប្រណម្យផ្គង់
បង្គំព្រះពុទ្ធគ្រប់ព្រះអង្គ ព្រះធម៌ព្រះសង្ឃប្រសើរសាយ។
ព្រះគុណគ្រូឧបជ្ឈាយាចារ្យ មាតាបិតាបង្កើតកាយ
បង្កើតប្រាជ្ញាថ្វាវៃឆ្ងាយ ខ្ញុំសូមអធិប្បាយចែកពាក្យជូន។
ព្រះពុទ្ធសករាជព្រះសាសនា អតិកន្តាកន្ទង់ធួន
ពីរពាន់បួនរយចិតសិបបួន ជូនខែនិងថ្ងៃគ្មានកន្ទង់ ។
ដើមឆ្នាំមមែក្នុងត្រីស័ក ពិសាខភ្លៀងធ្លាក់កាត់ទឹកម្តង
មួយពេចថ្ងៃសៅរ៍កើតសៅហ្មង លឺពាក្យអ្នកផងទាស់ទែងគ្នា ។
មិនបានកាប់ចាក់ដល់បាក់បែក ថ្ងៃនេះជជែកថ្ងៃស្អែកជា
ចាក់ដោតរាលពេលពោលពណ៌នា និន្ទាដៀលត្មះចាស់បុរាណ ។
ពួកចាស់ដៀលត្មះអ្នកប្រាជ្ញថ្មី រឿងធម៌បាលីស្តីប្រមាណ
ប្រមាថទៅមកមិនឈប់ខាន ហាមប្រាមមិនបានមិនបាត់មាត់។
ព្រះធម៌ព្រះពុទ្ធតែមួយអង្គ លោកសង្ឃបួសរៀនមានដោយវត្ត
សង្ឃខ្វះចេះស្ទើរមិនចាំស្អាត់ ភ្លើៗសូត្រភ្ញាត់មិនត្រូវខ្យល់។
គេចាប់ថាខុសប្រកាន់ខឹង មិនដឹងថាខ្លួនរៀនមិនដល់
មិនដែលសួរគេព្រោះមិនឆ្ងល់ សំគាល់ថាខ្លួនត្រូវមិនខុស។
អ្នកប្រាជ្ញលោកសូត្រចំបាលី ថាគេធម៌ថ្មីស្តីបន្ទុះ

បន្ទោសទៅមកឆ្លើយឆ្លងឈ្លោះ មិនព្រមចំណុះខុសចំណាំ ។
ចំណែកចំណោះចេះពល់ខ្លួន បាពជិកបួនវិន័យប្រាំ
មហាវគ្គចុល្លវគ្គអាទិកម្ម ព្រះអង្គគ្មានផ្តាំឲ្យឈ្លោះគ្នា។
ផ្តាំឲ្យតែកាន់សិក្ខាបទ អ្នកបួសរាល់វត្តត្រូវសាមគ្គា
ព្រះពុទ្ធរូបរាល់វិហារ វន្ទាគោរពរាល់យប់ថ្ងៃ។
នមស្ការបង្គំធម៌បីបទ សូត្រហបមាត់ទឿយជើងដៃ
មិនដឹងប្រាកដរតនត្រៃ មិនចេះសង្ស័យសួរអ្នកណា។
អ្នកប្រាជ្ញលោកសូត្រចំបាលី ប្រែចេញសេចក្តីឲ្យពិស្តារ
អ្នកខ្លៅមិនស្តាប់តាមពុទ្ធដិកា គេថាខ្លួនខុសប្រកាន់ខឹង ។
ធម៌សម្ពុទ្ធេសូត្រលាន់ៗ ព្រះពុទ្ធរយពាន់ខ្វះមិនដឹង
ជឿជាក់ថាចេះចប់ប៉ុណ្ណឹង មិនប្រឹងរៀនប្រែបកបរិយាយ។
ចេះហើយមិនដឹងថាខ្លួនខុស មិនព្រមចំណុះអ្នកប្រាជ្ញប្រាយ
បាលីច្រលំពាក្យនិស្រាយ នឹកស្តាយបែបចាស់មិនផ្លាស់ចេញ។
គេថាសូត្រធម៌មិនចេះប្រែ បានបុណ្យខ្វះដែរតែមិនពេញ
បើចេះប្រែផងបានចំណេញ ខ្លួនរិតទន្ទេញតែបែបចាស់។
ចចេសទទឹងរឹងជដែក ប្រកឹងប្រកែកប្រកួតម្នះ
ម្នៅៗសត្រូវនឹងធម៌ព្រះ ជាតិក្រោយក្រលាស់ជាល្ងង់ខ្លៅ។
មានកាលត្រលប់ជាគថ្លង់ មម៉េងមម៉ង់ឆ្កួតមួម៉ៅ
ពីព្រោះមិនស្តាប់ប្រាជ្ញប្រដៅ ហ្នឹងហៅចេះហើយមិនប្រសប់។

ប្រសិនបើឱនខ្លួនខ្វបខ្វាច
អ្នកប្រាជ្ញកាលណាលោកនឹងស្អប់
ធម៌អាថិអ្នកណានឹងចេះចប់
កុំកាន់ទំលាប់ទំលោយខ្លួន។
ទំលាក់ឲ្យទាបសុភាពវ័យ
ព្រះសូត្រវិន័យធំជាងក្បួន
ព្រះអភិធម្មជាមាំបួន
នេះហើយប្រជួនគួររៀនទៀត។
ពាក្យពីបុរាណជាពាក្យងាយ
ពាក្យក្បួនទូលាយស្រណុកជៀត
ឯពាក្យគម្ពីរទីចង្អៀត
គួរឆ្ងៀតជ្រើសរកយកឲ្យបាន។
ឲ្យបែកគំនិតគិតច្រើនផ្លូវ
មួយខុសមួយត្រូវជាពីរស្ថាន
គេប្រាប់ថាខុសគួរឈប់ខាន
ឃើញត្រូវប៉ុន្មានប្រមូលយក។
ព្រះឱស្ឋព្រះអង្គទ្រង់ទេសនា
អ្នកប្រាជ្ញចែងចារចង់ទុកមក
ព្រះសូត្រវិន័យលោកលៃលក
ប្រែសព្ទសៀតស៊កច្រើនប្រការ
ពាក្យពិតប្រាកដបទបាលី
ប្រែចេញសេចក្ដីឃើញពិស្ដារ
គួរស្ដាប់ឲ្យស្ដែងសិនកុំថា
កុំអាងតំរាតំរាប់ចាស់។
តំរាយបុរាណយូរអង្វែង
មិនលែងច្រលំមានលើសខ្វះ
អ្នកប្រាជ្ញជំនុំឃើញខុសណាស់
ចោលខ្វះទុកខ្វះដោយពិស្ដារ។
យ៉ាងធម៌«តិរោក»ពីបុរាណ
មិនដឹងជាបានពីគ្រូណា
សូត្រលាយចំរុះខុសអក្ខរា
មិនបានជាការប្រយោជន៍អ្វី។
អ្នកប្រាជ្ញឃើញខុសច្រើនអន្ទើ
រុះរើរៀបចំផ្សំបាលី
អ្នកខ្លៅហៅធម៌តិរោកថ្មី
សម្ដីបែបឡកចំអកខឹង។
សង្ខេបរឿងសូទ្រធម៌ត្រូវខុស
កូនចៅប្រុសៗគួរខំប្រឹង

ប្របរកអ្នកប្រាជ្ញប្រិតឲ្យដឹង សំលឹងអក្ខរាឲ្យប្រាកដ។
ប្រការមួយទៀតចាស់ជាន់មុន ធ្វើបុណ្យអភិសេកបែកច្រើនបទ
ច្រើនបែបរាប់អានគ្មានកំណត់ សន្មតថាធ្វើតាមបុរាណ។
អាចារ្យមួយប៉ែកអភិសេកខ្ចិល បង្វិលពពិលរំពេចបាន
អាចារ្យមួយថាធ្វើតាមបាន លំអានគម្ពីរបឋមត្រាស់។
ទេសទសជាតកចប់អភិសេក ព្រឹកស្អែករៀបចំមធុបាយាស
មានមារលើកពលច្បាំងដេរដាស ធ្វើប្រាសត្រលប់ក្រោយជាមុន។
បើធ្វើឲ្យត្រូវតាមសាស្ត្រា នាងនាថសុជាតាគេមានគុណ
ថ្វាយមធុបាយាសព្រះមានបុណ្យ និមន្តទៅផ្សងបីដងត្រាស់។
ទេវតាផ្អើលចុះពេញផែនដី គ្រប់ទិសប្រាំបីមីរដេរដាស
កក្រើកញាប់ញ័រទាំងអាកាស អរណាស់ថ្វាយសព្ទសាធុការ។
ហេតុនេះអ្នកចេះចាំនិទាន ធ្វើរោងធ្វើរានថ្វាយទេវតា
អ្នកប្រាជ្ញចេះថ្មីស្រដីថា អាចារ្យនាំធ្វើខាតប្រយោជន៍។
អាកាសទេវតានៅស្ថានខ្ពស់ គេខ្ពើមជាមនុស្សក្លិនអសោច
ឧស្សាហ៍ដាក់នំឲ្យហិចហោច ចំណោញស្រមោចចោមរោមស៊ី
អាចារ្យមួយទៀតចេះរៀបចំ ប្រណាម្យសំពះក្រុងពាលី
ព្រះឥសូរព្រះនារាយណ៍មានរិទ្ធី ពេញទីចោលត្រៃសរណគមន៍។
ចំណីចំណែកចែកដាក់ពៃ ចំណោញបានផ្តៃវាស៊ីនំ
នាងហ៊ីងធរណីថាជាធំ សូមសុំទឹកដីសាងកុសល។

អាចារ្យដាន់ចាស់ដោះសង្ស័យ ជារតនត្រៃគេតំកល់
តំកើងលើកឡើងជាដើមផល ប្តឹងដល់ទេវតាជាសាក្សី។
សង្ខារិករលឹកគុណ ធ្វើបុណ្យអភិសេកព្រះពុទ្ធថ្មី
បូជាភ្ញីផ្កាស្វាបារី គ្រប់ទិសប្រាំបីសឹងឲ្យមាន។
អភិសេកព្រះពុទ្ធតាំងកសាង តំណាងព្រះពុទ្ធដ៏ទ្រង់ញាណ
រំលឹកទេវតាជាប្រធាន ប្រាថ្នានិព្វានស្ពានផុតទុក្ខ ។
ថាបើទេវតាខ្ពើមចំណី ស្អប់ស្វាបារីមិនចង់ជក់
បិសាចភ្ញើៗមិនលែងភ្ញក់ អារុក្ខទេវតាមិនលែងសោយ។
នំនែកចំណីឆ្អែតស្អប់ស្អល់ សេសសល់បានប្រេតគ្នាស៊ីក្រោយ
ស៊ីគ្រាន់រួចរស់ព្រោះគេឲ្យ បានដោយមគ្គផលកុសលដារ ។
លោកសូត្រតិរោកតែរាល់ព្រឹក យំកិញ្ចិច្រូចទឹកថែមយថា
បញ្ជូនអានិសង្សដល់ដូនតា ប្រាថ្នាដូចម្តេចក៏សឹងបាន។
ក្រែងដូនតាណាទៅជាប្រេត រឺមួយអណ្តែតជាតិរច្ឆាន
លើសខ្វះប៉ុណ្ណោះខុសប៉ុន្មាន រាប់អានទេវតាប្រាថ្នាសុខ។
ថាបើទេវតាមិនព្រមសោយ កុំឲ្យខុសចុះនរក
នរកើតភាន់ផុតក្នុងភក់ រីវក់ក្នុងវាលវដ្តសង្សារ។
មិនដាច់សង្ស័យដូចអរហត្ត លោកកាត់កាមគុណនិងតណ្ហា
ត្រង់ភ្លឹងមិនដាក់ពឹងទេវតា ប្រាថ្នានិព្វានគ្មានត្រលប់ ។
ឃើញធ្វេងមិនផុតកពទាំងបី ធម៌អាថិបាលីចេះមិនចប់

មិនបោលសីលថកម្មបទ១០ រាវរៀបឲ្យសព្វកុំឲ្យសល់
សម្បត្តិសួគ៌សុខកើតពីទាន ឈោងយកនិព្វានឈានមិនដល់
មិនដើរហួសសោតាមគ្គផល តម្កល់និព្វានទុកដោយឡែក ។
នេះចប់ចំលើយអ្នកប្រាជ្ញចាស់ ប្រាជ្ញថ្មីចង់ឈ្នះប្រឹងប្រកែក
ប្រាកដនិព្វានជាស្ថានឯក ចំណែកសោតាក្នុងតែបាន។
ជ្រះថ្លាធ្វើបុណ្យក៏ធ្វើចុះ ទានណាខាតខុសត្រូវឲ្យខាន
អារុក្ខអារក្ខកុំរាប់អាន ជាស្ថានទាបថោករកធ្វើអ្វី ។
សង្ខេបរឿងសូត្រធម៌ត្រូវខុស កូនចៅស្តាប់ចុះទាំងប្រុសស្រី
អ្នកប្រាជ្ញពួកចាស់និងពួកថ្មី គប្បីចូលចិត្តជឿពួកណា។
បើរឿងសូត្រធម៌អាថិបាលី គួរចូលប្រាជ្ញថ្មីខំសិក្សា
ប្រយោគប្រធានមានមាត្រា រាជការបានជីប្រឡងជាប់ ។
ប្រាជ្ញចាស់ដាន់មុនធ្វើបុណ្យទាន ធ្វើរានទេវតាដោយសារធ្លាប់
អ្នកតោតល្ងង់ខ្លៅគ្នាខ្វាចង៉ាប់ អាចារ្យបង្គប់គ្នាធ្វើទៅ ។
បើបែរជាខានមិនបានសុខ មិនបានធ្លាក់ចុះនរកជ្រៅ
បើធ្វើទេវតាមិនជ្រកនៅ ស្ថានគេសន្ធៅសន្ធឹងហោះ ។
ហេតុនេះគួរគិតគួររំពឹង ជញ្ជឹងកុំឲ្យសល់ចន្លោះ
ចាស់មុនមានគុណរាប់មិនអស់ មិនឲ្យបោលសោះក៏មិនបាន។
គួរគិតឲ្យសព្វគ្រប់អន្ទើ គួរធ្វើរឺគួរបង្អង់ខាន
បើធ្វើមិនខាតបង់ប៉ុន្មាន បើខានក៏គ្មានទោសទាស់អ្វី។

ប៉ុន្តែមិនបាត់ពាក្យចាក់ដោត ជ្បិតមនុស្សច្រើនឆោតទាំងប្រុសស្រី
ពោលថាធ្វើបុណ្យតាមប្រាជ្ញថ្មី អាយុថយខ្ចីជាងដូនតា ។
ពាក្យនេះសង្ខេបស្ទេះមួយប៉ែក មានឈ្មោះប្រកែកច្រើនប្រការ
មិនចាំប្រាកដគម្ពីរណា ពោលថាទឹកដីនេះគ្មានគុណ ។
អ្នកប្រាជ្ញនាំឲ្យអ្នកខ្លៅឆ្ងល់ សាយសុសសួរដល់ពួកអ្នកមុន
អ្នកមួយរេរង់រែកពុន មិនទាន់ចូលស៊ុនស៊ប់ម្ខាងៗ។
អ្នកក្រោយបណ្តោយសួរអ្នកមុន ថាដីមានគុណប៉ុន្មានយ៉ាង
សំគាល់គោលអ្វីជាតីតតាង មានរាងឃើញក្នុងគម្ពីរណា។
រុកម្ខាងថាអាងនគរកាយ បរមត្ថអធិប្បាយក្នុងសាស្ត្រា
ជាតុទឹកតួ ន អង្គអក្ខរា ជាគុណមាតាពីរដណ្តប់។
ជាតុទឹករំលឹកពីសេម្ហំ វកំ យកនំ រហូតចប់
ជាតុដី កេសា មសំ សព្វ បញ្ចប់ បិត្តំ គុណបិតា ។
អ្នកចេះបិដកឆ្លើយបីដង ថានោះជាកងពួកកេសា
ហៅធម៌អាច់នោមក៏ល្មើមល្ហា អ្នកណារំលឹកគ្មានប្រយោជន៍។
អ្នកមួយថាភាវនាកុំឈប់ ជាទីអសុភផ្លូវអសោច
អសារឥតការស្លាប់ជាខ្មោច គេដុតឆេះខ្លោចគ្មានខ្លឹមសារ។
គួរគិតកុំស្តាយកុំស្រណោះ រូបរាងទាំងអស់ជាអនិច្ចា
អនិច្ចំមិនទៀងល្បៀងសង្ខារ សង្ឃឹមរូបានេះមិនបាន។
សរសៃរសាច់ស្បែកសង្កេតគ្រប់ ជាសាកអសុភកម្មដ្ឋាន

របស់ខាងក្នុងទាំងប៉ុន្មាន មុខជាមិនខានរលាយបាត់ ។
ទឹកដីខាងក្រៅក៏មានគុណ ព្រោះដីកើតមុនទើបកើតសត្វ
កើតសព្វរូបកាយអធិប្បាយកាត់ លើកឡាត់លះឃ្លាឲ្យយ៉ាងខ្ជី។
គម្ពីរត្រៃវេទដើមសាសនា ត្រៃយុតត្រៃតាគ្រប់ជាបី
ព្រះពុទ្ធចេញសាងអាងទឹកដី សន្សំបារមីក្នុងភទ្ទកប្ប។
ភទ្ទកប្បនេះមានព្រះពុទ្ធ៥ បានរៀនចេះចាំជាសណ្ដាប់
សំដែងថាចុះនរកមួយកប្ប លោកប្រាប់ថាជេរព្រោះទឹកដី។
អ្នកម្នាងថាអាងរៀនសាស្ត្រា ប្រែអស់គាថាបទបាលី
ព្រះពុទ្ធទតគ្រប់ភពទាំងបី ត្រង់គុណទឹកដីមិនឃើញមាន។
កេសាអក្ខរាទាំង៥តួ មិនគួរបើយកមកសន្និដ្ឋាន
យើងចេះដឹងដែរតែមិនហ៊ាន ដូចពោលបំពានហួសពុទ្ធដិកា។
ពាក្យនេះអ្នកខ្លៅកើតសង្ស័យ សព្វថ្ងៃនៅក្នុងខេត្តា
មិនទាន់ដាច់ស្រេចទៅខាងណា មិនឃើញពិស្ដារស្ដាប់មិនបាន ។
ម្យ៉ាងទៀតប្រាជ្ញថ្មីស្ដីដៀលត្មះ ចង្ហាន់ថ្វាយព្រះថាឲ្យខាន
ដ្បិតព្រះមិនឆាន់នៅពេញចាន របស់ប៉ុន្មានបានអាចារ្យ។
របៀបរាប់បាតមានកន្ទោង ១ឈេង២ឈោងហៅបាយដារ
បាយដាក់ហ្នឹងតើឲ្យអ្នកណា អសារឥតការឥតប្រយោជន៍។
ព្រះពុទ្ធមិនឆាន់មិនចេះស្ដី យើងអាងបាលីឧទ្ទិសដល់
តម្កើងចង្ហាន់លើកតំកល់ សេសសល់ប្រគេនេនសាមណេរ

សមណៈបួសរៀនមានសីលដប់ ប្រសប់ប្រសើរគ្រាន់បើដែរ
បញ្ជូនមគ្គផលដល់ឪម៉ែ បង្វែរឧទ្ទិសតាមប្រាថ្នា។
អ្នកវេគំនិតគិតតែកាញ់ ចូលបទកំណាញ់ក្រៅតំរា
ទុកស៊ីមាត់ឯងឲ្យឆ្ងាញ់ពិសា ខ្វាចបានអាចារ្យស៊ីខាតទុន។
អ្នកម្ខាងថាអាងដាក់ឲ្យប្រេត ដោយហេតុគ្នាឃ្វានគ្នាហិនហោច
គ្នាស៊ីខ្ទុះឈាមក្ទិនអសោច បិចបោចចែកទានគ្នាស៊ីផង។
ប្រេតត្រូវជាញាតិធម៌តិរោក គ្នាបានងើបមកព្រោះគេផ្សង
បានស៊ីដោយសារដារម្តង។ បានដូចបំណងបំណាច់នឹក។
ចង្ហាន់ថ្វាយព្រះត្រូវបូជា អាចារ្យវន្ទាសូត្ររំលឹក
ព្រះពុទ្ធមានគុណមុនលោកភិក្ខុ បាយទឹកជាទានមានមគ្គផល។
ម្យ៉ាងទៀតប្រាជ្ញថ្មីស្រដីផ្តាច់ ថាពូនភ្នំខ្សាច់មិនបានបុណ្យ
ដីកដីលៀនភ្នែករែកត្រុន ដឹងបានជាគុណប្រយោជន៍អ្វី ។
នាំគ្នាអុជធូបហែទក្សិណា អាចារ្យនោះឆ្អិនខាងបាលី
ហើយមានចេះធម៌បំបួសដី មិនដឹងជាដីឆ្លើយថាម្តេច។
អ្នកមួយថាពូនភ្នំខ្សាច់ស្អាង តំណាងចេតិយព្រះសរពេជ្ញ
ព្រះសារីរិកធាតុយើងមិនភ្លេច ដ្បិតបុណ្យយើងតិចទៅមិនដល់។
បើធ្វើដោយវាលកណ្តាលថ្ងៃ គង់ជាប់និស្ស័យបានកុសល
បើដើមពោធិ៍ពិតរឹតបានផល តំកល់ដើមពោធិ៍យកជាម្ចប់។
ពូនភ្នំតំកើងពោធិព្រឹក្ស រលឹកដល់អង្គព្រះចមភព

ប្រក្តារ៤ផ្ទាំងបង្ខាំងផ្ទប់ កុំឲ្យកំពប់ហៀរហូរដី ។
បើចេះរំលឹកបានបុណ្យណាស់ ជឿចុះប្រាជ្ញចាស់កុំជឿថ្មី
ប្រាជ្ញចាស់ក៏ចេះប្រែបាលី បរលោកលោកិយក៏ចាស់ដឹង ។
ចាស់ម្យ៉ាងចាស់ពិតគំនិតពាល ចាក់ដោតពោលរាលនាំក្មេងខឹង
ចាស់ម្យ៉ាងផឹកស្រាក្លាស្រវឹង ចាស់ហ្នឹងហៅក្មេងក៏សឹងបាន។
ចាស់ជាន់ពីមុនច្រើនខ្វាចច្បាប់ ធ្វើតាមតំរាប់ចាស់បុរាណ
បុរីនគរធ្លាប់រាប់អាន តែខានខ្វាចខុសក្បួនតំរា។
ច្រើនជឿតំរាប់ក្បួនលោកិយ មានកូនប្រុសស្រីត្រូវរៀបការ
សំលាប់ជ្រូកមាន់ស៊ីហ៊ឺហា ផឹកស្រាលៀនភ្នែកជជែកឈ្លោះ
បណ្តោយឲ្យយកគ្នាទទេ មេបាធ្វើគេក្រែងមិនរស់
នាំកូនសែនខ្មោចអសោចឈ្មោះ ពីព្រោះមានប្តីមិនរៀបការ។
រៀបកិច្ចមង្គលមានច្រើនយ៉ាង ពួកចាស់ច្រើនអាងក្បួនតំរា
បើតាមតំរាយព្រះសូត្រថា មេបានាំកូនចុះនរក ។
បុត្តទារស្ស សង្គហោ ហីនោ គាមោ ធម៌អ្នកស្រុក
សង្គ្រោះកូនផុងទៅក្នុងភក់ ហ្នឹងហៅអាពុកពន្ធិចកូន។
បើធ្វើមង្គលឲ្យរួចបាប រួចពៀរដរាបអស់តាដូន
មង្គលយ៉ាងល្អបរិសុទ្ធសូន្យ ប្រមូលបងប្អូនស៊ីម្ហូស្វា។
ជ្រូកមាន់កុំបាច់សំលាប់ តែសាកមានស្រាប់ទិញពីផ្សារ
ផ្សំកូនប្រុសស្រីតាមមេបា អាចារ្យប្រមូលអស់ចាស់ទុំ។

ប្រុសស្រីអង្គុយកាន់ពពិល បង្វិលប្រាំបួនដណ្ដប់ជុំ
ធ្វើកិច្ចមង្គលក្នុងជំនុំ ផ្សំផ្គុំកូនប្រុសនិងកូនស្រី ។
ចាស់ៗធ្វើច្រើនធ្វើក្នុងឆោត ចង់ឲ្យគេកោតនាលោកីយ
យើងធ្វើយាងតិចត្រលេចខ្ចី បានប្តីប្រពន្ធដូចៗគ្នា ។
ហៅកូនសង្គ្រោះម្ដាយឪពុក រួចទោសរួចទុក្ខអស់មីងមា
អាពុកសង្គ្រោះគ្មានវេរា អាវាហ៍វិវាហមង្គល។
មិនគួរបង្គាប់ឲ្យកោរជុក ហេតុម្ដាយអាពុកនាំរវល់
អាចារ្យតែងក្បួនឲ្យអំពល់ ពន្យល់អ្នកល្ងង់ឲ្យបង់ទ្រព្យ។
អ្នកខ្ជិលគេជឿសីលមាំមួន ពាក្យក្បួនតំរាគេមិនរាប់
គេថាមិនរស់ពីព្រោះធ្លាប់ មិនស្លាប់ពីព្រោះមិនធ្វើធ្មេញ ។
យ៉ាងដូចចិនយួននៅដាក់ផ្សារ ស្រុកស្រែចំការក្រុងភ្នំពេញ
កើតឡើងជុះសក់មិនកោរវិញ រវល់ដូរទិញអង្គុយលក់ ។
ប៉ុន្តែជាតិចិនល្មោភស៊ីសាច់ តមដាច់មិនដែលស៊ីប្រហ៊ក់
ខ្មែរៗប្រហែលខ្វះម្ទេសជ្រក់ ទូលស្រូវកន្ទក់ទៅដូរចិន ។
ហេតុតែជាខ្មែរសម្បុរខ្មៅ គំនិតគិតឆៅមិនសូវឆ្អិន
រកស៊ីមិនឆ្អែតជឿចៃសិន អាចឹកវាកិនទារទាល់បាន ។
១កើតអស្សុជសំលាប់មាន់ ចំអិនគ្រប់គ្រាន់ដួសដាក់ចាន
រៀបសែនព្រះភូមិតាមបុរាណ ថាខានខុសក្បួនប្រពៃណី ។
ហ្នឹងហៅចាស់ឆោតនាំក្មេងព្រើល ហែកមាត់មាន់មើលចង្កាពីរ

អាដែងព្រះភូមិមានឈ្មោលញី ជាសែនរកស៊ីបានផលស្រូវ។
មានជូនជូនតាទៅស្រុកប្រេត បណ្ដោតសំបានប្រានសំពៅ
សំពះអារក្ខជូរខាងឪ ខាងម៉ែក៏ត្រូវមិនសូវខុស។
ថ្វាយចេកថ្វាយស្រាជារង្វាន់ ខ្មោចចូលជិះជាន់រូបស្រីប្រុស
កូនចៅអើយជឿពុទ្ធដិកាចុះ រូបស្លាប់ពីព្រោះតែផលកម្ម។
រូបសុខដោយសារតែផលបុណ្យ កាលជាតិពីមុនខ្ជាប់សីល៥
ជាតិនេះអាយុអង្វែងឆ្នាំ កូនចៅអ្នកចាំជឿឲ្យជាក់។
ឲ្យពិចារណាចិត្តឯង ស្ដាប់ធម៌ម្ដងៗគួរឲ្យភ្ញាក់
កុំផ្ញើរូបកាយនឹងអារក្ខ ក្រែងធ្លាក់ទៅក្នុងចតុរាបាយ។
បើចង់អាយុវែងយឺនយូរ គោរពគុណគ្រូអាពុកម្ដាយ
បើចង់រកស៊ីសុខសប្បាយ ផ្ញើកាយនឹងគុណរតនត្រៃ។
នមស្ការបង្គំពេលល្ងាចព្រឹក ភាវនារំលឹកពល់យប់ថ្ងៃ
កុំថាធម៌ណាថោកណាថ្លៃ សង្ស័យត្រូវសួររាជបណ្ឌិត។
កុំឲ្យមន្ទិលធម៌ថ្មីចាស់ មួយធម៌ក្រដាសមួយធម៌ស្លឹករិត
រាជការជំនុំរួមគំនិត រិះគិតតំកើងព្រះសាសនា។
តំកល់សីលប្រាំសីលប្រាំបី ឲ្យមនុស្សប្រុសស្រីរួមរក្សា
ផ្ទាត់ផ្ទៀងខ្ចាបល្បៀងព្រះពុទ្ធដីកា ពិនិត្យអក្ខរាយកត្រឹមត្រូវ។
ជំនុំបោះពុម្ពដាក់ក្រដាស ជាការរហ័សធ្វើសៀវភៅ
ឲ្យមានសូត្ររៀនច្រើនតទៅ ទុកនៅជាកេរ្តិ៍អង្វែងឆ្ងាយ។

សព្វថ្ងៃអ្នកខ្មៅស្អប់អ្នកប្រាជ្ញ　　ពោលខ្លាំងគិតខ្លាចលីសុសសាយ
ជាធម៌សៀវភៅធម៌ក្មេងក្វាយ　　អធិប្បាយខ្សឹបៗតែគ្នាឯង។
ឲ្យស្ងៀមពីថ្ងៃនេះតទៅ　　ឯធម៌សៀវភៅផែនដីតែង
មិនមានអ្នកប្រាជ្ញណាហ៊ានក្មេង　　ខ្លាចក្រែងរាជការចាប់ដាក់គុក។
គម្ពីរស្លឹករឹតជាគំរូ　　តំកល់ក្នុងទូចាក់សោទុក
គម្ពីរសៀវភៅប្រើគ្រប់មុខ　　ទំនុកបំរុងក្នុងសាសនា។
ចាស់ៗជាន់មុនមានគំនិត　　គម្ពីរស្លឹករឹតជួលគេចារ
ពុំនោះជាវគេដោយជ្រះថ្លា　　ច្រើនមានប្រាជ្ញាតិចអ្នកចេះ។
សង្វេបបទបែបរឿងប្រដៅ　　ទូន្មានអ្នកខ្មៅឈប់ទុកស្ទេះ
សុំកើតអ្នកប្រាជ្ញមានតំរិះ　　កុំតិះដៀលត្មះចាស់ជាន់មុន។
កុំថាចាស់ល្ងិតល្ងង់ល្ងីល្ងើ　　ក្រែងពារទៅលើអ្នកមានគុណ
កុំពោលថាចាស់ថយថោកធុន　　ក្រែងស៊ុនទៅលើគ្រូអាត្មា។
ដ្បិតសិស្សនិងគ្រូមិនអ្នកក្រៅ　　ជាក្មួយជាចៅជាជីតា
ជាសាច់ខាងមាតាពីបិតា　　ជាកម្មវាចាខ្លះជាបង។
ខ្លះត្រូវជាធំខ្លះត្រូវជាមា　　ជាគ្រូឧជ្ឈាយ៍បំបួសផង
ប្រដៅសព្វថ្ងៃវាយម្តងៗ　　ព្រោះលោកបំណងចង់ឲ្យចេះ
ដល់ខ្លួនរៀនចាំដាក់បាលី　　ឡើងពាក្យសំដីអាងតំរិះ
តំរូវខាងណោះខុសខាងណេះ　　ដៀលតិះថាគ្រូខ្លួនឯងល្ងង់។
លោកគ្រូមិនដឹងប្រឹងតែអរ　　ខំផ្ញើអង្គរបាវការុង

ស្គរក្អមស្គរស្រាក់លាក់មិនគង់ ចង់ផ្ញើពូជពង្សល្បីកេរ្តិ៍ឈ្មោះ។
ខ្លួនចេះបន្តិចតំប៉ិចឡើង ចចើងចចេសជជែកឈ្លោះ
ចេះកប់ពពកយកកំពស់ បន្ទុះបន្ទន់គុណទាបទៅ។
បើចិត្តចង់ធំកុំចចើង គួរលើកតំកើងគុណទុកនៅ
ទោសនោះធ្លាក់ចុះនរកជ្រៅ ម្នៅៗឲ្យបាបពីព្រោះមាត់។
ព្រោះមាននិទានពុទ្ធឃោសា អាងចេះសាស្ត្រាគម្ពីរស្ទាត់
ថាចេះលើសគ្រូៗបំភ្លាត់ បំប្លែងកំចាត់ឲ្យទណ្ឌកម្ម។
ប្រដូចនិទានតែប៉ុណ្ណោះ អស់លោកក៏ចេះបានរៀនចាំ
ផ្តួចផ្តើមមួយឃ្លាជាពាក្យផ្តាំ ដូចមានចំណាំចំណោទជូន។
ទំនុកបុរាណមានប្រាជ្ញា ចេះចែងបញ្ហាសាស្ត្រាក្បួន
ទុកឲ្យអ្នកក្រោយដោះសំនួន បើគិតឲ្យមួនគួរមានភ័យ។
ចំណោទថាសត្វបរោខា អង្គុយមែកឈើស៊ីផ្លែជ្រៃ
បុរសខុសជ្រុលគ្មានលក់ព្នៃ បង់គោក្របីទាំងមេកូន។
បុរសម្នាក់ទៀតឡើងដើមឈើ បេះផ្លែខាងលើចែកបងប្អូន
ស៊ីផ្អែតបន្តិចភ្លេចគល់សូន្យ បុរសម្នាក់បានកូនភ្លេចគុណម្តាយ។
ចំណោទទីបីចំណែកនេះ គួររិះឲ្យជិតកុំគិតឆ្ងាយ
កុំឆ្ងល់និងពាក្យពោលអធិប្បាយ ប្រឹងគិតដោះស្រាយប្រាជ្ញាស្រាប់។
និយាយដើមគ្រូដោយកំបាំង មានខ្សឹបមានខ្លាំងពោលបង្អាប់
បង្អើលឲ្យអ្នកដទៃស្តាប់ បង្អន់ដូចកាប់គាស់ឫគល់។

ស៊ីផ្លែឆ្ងាញ់ផ្អែមតាមទុំខ្ចី
ឬលិចក្នុងដីមើលមិនយល់
មិនយកដីចាក់កប់គុណទល់
អំពល់ឲ្យបាបអំពីមាត់។
ពីមុនកាលកើតមានរូបកាយ
អ្នកម្ដាយចិញ្ចឹមបានធំធាត់
នាំយកទៅទុកឲ្យនៅវត្ត
រៀនចេះចាំស្ទាត់បំភ្លាត់គុណ។
ភ្លេចគោក្របីទាំងមេកូន
សាបសូន្យកុសលដែលមានមុន
សាងក្រោយសាងឲ្យតែខាតទុន
ពីព្រោះបាបស៊ុនស៊ិយពីចិត្ត។
ពិចារណាគួរតែកោតខ្លាច
ខ្លួនបានជាប្រាជ្ញព្រោះគ្រូប្រិត
ប្រឹងប្រៀនប្រដៅច្បាប់ក្រមក្រិត្យ
អាណិតដល់គុណធ្ងន់អនេក។
អនាគតកាលទៅមុខ
ចូរចាំចងទុកដល់ស្អែក។
កុំស្អប់ចាស់ថ្មីស្ដីដោយឡែក
មើលចែកចាត់ចិត្តថ្លឹងឲ្យស្មើ។
ធ្វើបុណ្យដោយស្មោះកុំរើស្ម័គ្រ
បាលីបីថ្នាក់ចាំហើយតើ
មនោសេដ្ឋំចិត្តប្រសើរ
ប្រសប់គ្រាន់បើធ្វើបុណ្យបាន។
ប្រាជ្ញថ្មីធ្វើតិចធ្វើតាមចុះ
កុំថាគេខុសហើយឈប់ខាន
ប្រាជ្ញចាស់ច្រើនធ្វើតាមបុរាណ
ច្រើនលើសប៉ុន្មានបានដោយបទ។
កុំធ្វើដោយរាប់អានស្រលាញ់
ទុកជាកំណាញ់ហួសកំណត់
កំណើតមគ្គផលជឿប្រាកដ
សន្មតថាបានច្រើនប្រការ។
កុំធ្វើប្រកាន់ដោយយល់មុខ
ហៅបុគ្គលិកទានគ្មានផលា
តាំងចិត្តចុះផ្លូវខេត្តា
រក្សារូបសុខដល់សួគ៌នាយ
សួគ៌នេះបើចង់ឲ្យធាប់ដល់
សាងមគ្គសាងផលកុំរាយមាយ

ឃើញគេខុសចិត្តកុំមើលងាយ កុំពោលនិយាយកាន់ម្ខាងៗ។
អ្នកប្រាជ្ញចេះថ្មីត្រូវដោយឡែក ចំណែកប្រាជ្ញចាស់ត្រូវដោយយ៉ាង
កាន់យកទាំងពីរជាទីអាង សន្សំខំសាងនឹងបានសុខ។
ពីថ្ងៃនេះទៅនៅឲ្យនឹង ស្មៀមមាត់ឲ្យឈឹងខ្វាចនរក
ពីព្រោះឈ្លោះគ្នារៀងរាល់ស្រុក បឹងថ្លុកត្រពាំងរាំងប្រេះដី។
មិនឈ្លោះពីរឿងកេរឿងកោះ រឺទ្រព្យរបស់គោក្របី
នេះឈ្លោះពីធម៌ចាស់ធម៌ថ្មី ក្តៅចិត្តកើតក្តីរកចាញ់ឈ្នះ។
បើក្តីពីស្រែពីចំការ ចៅក្រមសាលាងាយជំរះ
នេះក្តីពីធម៌ថ្មីធម៌ចាស់ នោះត្រែងតែព្រះទើបកាត់បាន។
ចៅក្រមសព្វថ្ងៃខាសក ចេះខ្ទេចបិដកព្រះកម្មដ្ឋាន
កាត់ក្តីត្រូវច្បាប់អំបាលម៉ាន អ្នកក្តីមិនខានប្តឹងឧទ្ធរណ៍។
អាដែងមនុស្សម្នះរឹងចចេស បានតែនិរទេសក្រៅនគរ
តែទុកវានៅវានាំវរ ជំហរតែរឹងទទឹងច្បាប់។
សង្ខេបបែបបទរឿងប្រដៅ អ្នកលិ្ងតល្ងង់ខ្លៅគួរតែស្តាប់
អ្នកចេះសូត្រធម៌មិនស្តាប់ស័ព្ទ គួរត្រាប់អ្នកប្រាជ្ញចេះបាលី
ធ្វើបុណ្យធ្វើទានកុំចោលចាស់ ចោលចេញទុកខ្វះក្បួនលោកិយ
សូត្ររៀនតាមបែបអ្នកប្រាជ្ញថ្មី កុំបីភ្លេចគុណចាស់បុរាណ
ធម៌អាថិច្រលំកុំច្រលោត ពាក្យពោលចាក់ដោតឲ្យឈប់ខាន
រួមចិត្តសះសាបានសុខសាន្ត នឹងឲ្យរុងរឿងរីកសាសនា។

កុំឲ្យវៀវពោយរឹតរង់កម្ម
រាំងរឹងរាល់ឆ្នាំថវស្សា

វស្សន្តរដូវត្រូវមនុស្សថា
រំដួលទេវតាក្តៅក្រហាយ

មនុស្សភូតកុហកឆក់ឆរបោក
ឆ្នាំនេះស្រូវថោកវាស្ត្រអត់បាយ

ក្រលុយក្រកាក់ខ្វះប្រាក់ចាយ
មហាជនទាំងឡាយកើតវេទនា

កិរម្យខ្ញុំបាទដើមឈ្មោះអ៊ូ
ពូជពង្សអំបូរខ្មែរអ្នកជា

អាពុកឈ្មោះ អ៊ុក មានសក្តិងារ
ចៅពញាធម្មធារាមេស្រុក

ក្នុងខេត្តភ្នំពេញ ឃុំកំបូល
ពូជពង្សត្រកូលម្ចាស់អង្គប៉ុក

ជីតាខាងម្តាយឈ្មោះពញាម៉ុក
គាត់ធ្វើមេស្រុកឃុំស្ពានថ្ម

អ្នកម្តាយអាពុកបងប្អូនជិត
ជីទួតមួយពិតពូជចិត្តល្អ

ដូនតាផ្សំផ្គុំជាតំណ
បង្កកើតមកជាខ្ញុំបាទ

ពូជខាងអាពុកមានប្រាជ្ញា
ច្រើនចេះសាស្ត្រាចាំក្បួនខ្នាត

ត្រកូលខាងម្តាយប្រាជ្ញាឆ្លាត
រូបរាងច្រើនស្អាតគ្មានគស្អប់ ។

ខ្ញុំលឺមនុស្សឈ្មោះពីធម៌អាចិ
គិតក្រែងសាសនាប្រែត្រលប់

ខ្ញុំចាប់អធិប្បាយពុំសាយសព្វ
សន្មតថាចប់ម្ល៉េះឯងហោង។

# ច្បាប់កេរកាលថ្មី

នេះបទព្រហ្មប្រាជ្ញប្រាយ ខ្ញុំអធិប្បាយលើកល្បត់ល្បង
ប្រដៅកូនចៅផង ចងជាច្បាប់ខុសនិងត្រូវ។
កត្តិកខ្មើតគ្មេរគ្មាន់ ក្នុងវស្សន្តរដូវ
ទឹកស្រែជនលេចស្រូវ នៅសំណល់សំណាបខ្ចី។
កិរកាលពីព្រេងព្រឹទ្ធ ដើមគំនិតពីសេដ្ឋី
ខ្ញុំលើកកិរកាលថ្មី តែងសេចក្តីជាបរមត្ថ។
ក្នុងថ្ងៃពេញបរមី ម៉ោង៨ព្រលប់ស្ងាត់
ឆ្នាំចរចត្វាក្សត្រ ផាត់សករាជកន្ទងឆ្ងាយ។
សាសនាព្រះសមណ: បានពីរពាន់បួនរយថ្វាយ
ហុកសិបឆ្នាំកំចាយ ចាត់អធិប្បាយពីខុសត្រូវ។
កិរកាលដំណាលទុក ជាទំនុកដំណែលនៅ
តំណតរៀងទៅ តំរូវចិត្តជនប្រុសស្រី។
កូនអើយពាក្យអាពុក ជាទំនុកទំនើបថ្មី
អនិស្រាយរាយបាលី អាពុកស្តីឲ្យកូនស្តាប់។
គួរស្តាយកេរ្តិ៍ម៉ែឪ កិរិយាត្រូវឲ្យខំត្រាប់
កិរិយាណាខុសច្បាប់ គួរក្រឡប់ក្រឡាស់ចោល។
ម្តាយអាពុកនិងកូន បីដូចខ្លួននិងស្រមោល

ឃើញខុសកុំដេញដោល កុំថ្កោលទោសអ្នកមានគុណ។
ល្ងង់ខ្លៅត្រូវតែសួរ ពាក្យឲ្យគួរកុំឲ្យស៊ុន
យកពាក្យផ្អែមជាមុន ទន់លំទោនឱនប្រតិបត្តិ។
ទោះឪម៉ែស្លូតកាច គួរតែខ្លាចដូចមហាក្សត្រ
ម្ដាយដេរពីរបីមាត់ គួរតែស្ងាត់ស្ងៀមឲ្យឈឹង
ប្រដៅត្រូវតែស្ដាប់ យកតំរាប់កុំទទឹង
ម្នោះម្នះចចេសរឹង នឹងហើយហៅកូនសេសកម្ម។
ធម៌អាថិចេះតែភ្លេច ដេរប្រទេចចេះតែចាំ
អាពុកពត់ទៅស្ដាំ អកុសលកម្មទាញទៅឆ្វេង។
អវជាតិបុត្រ ខូចបំផុតតាំងពីក្មេង
ប្រព្រឹត្តព្រើលផ្សេងៗ បើលេងអ្វីស្ដីមិនស្ដាប់។
មិនស្ដាយជាតិកំណើត ល្ងង់ស្លុតស្មើតដល់ចាស់ស្លាប់
ត្រឹមត្រូវមិនសូវស្ដាប់ ព្រួយគេប្រាប់ទាំងយប់ថ្ងៃ។
ម៉ែឪមានគុណណាស់ មិនសំពះខ្លាចអៀនដៃ
បើអ្នកក្រៅដទៃ វិស័យសោះសំពះបាន។
ឆ្លើយបាទចះចាំ៎ខ្ញុំ រាបរម្យទមនឹងសន្ដាន
ម៉ែឪឯងក្នុងឋាន ហ៊ានឆ្លើយអីអញអឺអើ។
អនុជាតិបុត្រ ស្លូតបំផុតស្រណុកប្រើ
ប្រកបការប្រសើរ ដើរតែតាមលំអានឪ។

ប្រដៅទទួលយក ចេះលៃលកស្ដាប់ខុសត្រូវ
ស្រណុកញាក់ធ្លាក់ផ្លូវ មិនសូវក្មេងដំបូន្មាន។
អតិជាតិបុត្រ ល្អបរិសុទ្ធស្ដាប់សីលទាន
នាំឪទៅនិព្វាន ឈានទៅរកកន្ទែងសុខ។
ចេះលើសគេដរាប ជឿបុណ្យបាបប្រេតនរក
មិនល្មោភនឹងមូត្រលាមក ភ័យនឹងភក់ភពសង្សារ។
នេះគឺដើមបាលី បុត្រទាំងបីបែបកិរិយា
ស្រលាញ់ណាស្អប់ណា តាមសញ្ញាចូលចិត្តចុះ។
អវជ្ជាក់ផ្លូវក្រោម ប្រព្រឹត្តព្រមតែខាងខុស
អតិជាតិមារយាទខ្ពស់ អនុនោះយ៉ាងកណ្ដាល។
មតិ១០០មានមួយ គួរតែស្ងួយដាក់លើក្បាល
អវគឺស្រើបស្រាល ត្រអាលយកតែពីរយ៉ាង។
អតិជាតិកំណើត គំនិតកើតពីកសាង
កុសលតំកល់ខាង សំណាងកើតពីគំនិត ។
អនុអានាងអើយ ខ្លួនធំហើយឲ្យចេះគិត
ចេះកាញ់ស្គាល់ឆ្ងាយជិត ប្រព្រឹត្តយកតែខាងត្រូវ។
រៀនរិះរកទ្រព្យធន យកប្រពន្ធមើលធុនឪ
ធុនបើកជ្រកខុសត្រូវ អ្នកកុំទៅខ្វាចបន្ទា។
ផ្លូវវៀចកុំបោះបង់ ផ្លូវព្រៃត្រង់កុំយាត្រា

ឈានឈរពិចារណា ធ្លារឲ្យស្អាតសឹមដើរទៅ។
កុំដើរភ្លើភ្លេចខ្លួន ខ្លាចក្រែងជួនធ្លាក់ជ្រោះជ្រៅ
ជ្រកម្លប់សំណាក់នៅ កុំបោះពៅផ្ទប់គល់ឈើ។
ឆេះខ្លោចសំបកក្រោម ស្រពោនញមស្មោកស្មឹកលើ
មានភ្នែកឲ្យបេះមើល កុំល្ងីល្ងើល្ងង់ល្ងិតពេក។
រៀនដើរឲ្យមើលផ្លូវ ធ្វើស្រែស្រូវឲ្យមើលមេឃ
ម្លប់ធ្លកធ្លាប់ជ្រកដេក ជាដំណេកអ្នកដំណើរ ។
ដំណែលដែលគេដាក់ ជាដំណាក់ទំនួលផ្ញើ
ចំណាំចាំគ្រាន់បើ ដើរក្រោយៗគ្រាន់ជ្រកទៀត។
ឈើណាទោសសត្រូវ ដុះជិតផ្លូវនាំចង្អៀត
ជំពប់យប់អាធ្រាត្រ ឆ្កៀតកាប់ចេញកុំទុកវា។
បន្ទាគល់សង្កត់ គន្ធងផុតតែភ្នែកជា
ដើរយប់ជំពប់ពារ ក្រែងគ្រោះគ្នាអ្នកដើរក្រោយ។
គ្នាមុតកុំចាំផ្ទាន់ ឃើញគួរជាន់កុំបណ្តោយ
បណ្តើរមើលខ្ចាំងខ្សោយ ឲ្យពិនិត្យពិចារណា។
ពាក្យពិតត្រង់ប្រាកដ ត្រូវច្រើនបទច្រើនប្រការ
ប្រកបជាប្រស្នា ប្រាជ្ញាអាប់ស្ទាប់នឹងធ្ងល់។
ផ្លូវពិតទាំងជិតឆ្ងាយ សព្វសុសសាយមិនសេសសល់
អ្នកណាប្រាជ្ញាដល់ ដឹងយោបល់ច្រើនកន្ទែង។

កូនអើយការកេរ្តិ៍ឈ្មោះ កុំចង់រស់តែម្នាក់ឯង
គិតអ្វីគិតឲ្យវែង ក្រែងក្រក្រោយសិយគំនិត។
កំណើតពលរូបកាយ ចេញជួញឆ្ងាយស្គាយជួញជិត
ចិញ្ចឹមជន្មជីវិត គិតឲ្យស្រេចទើបបានស្រួល។
ធ្វើស្រែចង់បានស្រូវ ដើមរដូវធ្វើស្រែទួល
ស្រែទាបមើលទំនួល លើកទំនប់ឲ្យមាំមួន។
កូនអើយកេរ្តិ៍មេបា ថាំរក្សាមើលថែថួន
ធុញថប់ថយថោកខ្លួន ដួនជាខ្សត់គេថាខ្សោយ។
ស្រូវខ្សោយអង្ករថ្លៃ លក់សំចៃទុកឆ្នាំក្រោយ
អ្នកក្ររកញយៗ ឲ្យអ្នកសុំជាងអ្នកខ្ចី។
សប្បុរសពេកថយធន មួទូជនថយរាសី
ប្រពន្ធល្អច្រើនអាប់ប្តី ពាក្យអប្រិយចាញ់អាត្មា។
ឈើផ្លែចាញ់សន្ទឹក ត្រីវររឹកទឹកមិនថ្លា
កំណាញ់ក្រៅតំរា សោតសឹងអាប់ប្រយោជន៍យស។
នឹងឲ្យៗមើលភាព ឲ្យអ្នកទាបជាងអ្នកខ្ពស់
អ្នកទិញឈប់សិនចុះ ក្នុងតែរស់មិនស្លាប់ងាយ។
កំណាញ់ហួសកំណត់ ពាក្យអ្នកខ្សត់ខ្សបនិយាយ
ទេវតាផ្តន្ទាទាយ រលាយអស់រលស់ឯង ។
សទ្ធាមើលធនធាន ជាតិអ្នកមានមិនអង្វែង

| | |
|---|---|
| កំណាញ់ដោយកន្ទែង | ក្រែងគ្រោះក្រដល់ឆ្នាំក្រោយ។ |
| អ្នកក្រខ្ចីនេះកុំ | អ្នកមានសុំនេះគួរឲ្យ |
| អ្នកប្រាជ្ញអង្គាសញយ | អស់ក៏ដោយឲ្យទៅចុះ។ |
| អ្នកក្របានជាហាម | ពិបាកតាមទៅឯណោះ |
| ទាល់ទឹកចូលច្រមុះ | ច្រើនកើតឈ្លោះពីព្រោះយល់។ |
| អ្នកមានគេមានខ្មាស | សងរហ័សមិនអំពល់ |
| ជួនយើងមានរវល់ | គេស្គាល់មុខស្រណុកខ្ចី។ |
| អ្នកក្រៗទាំងចិត្ត | ស្រូវធ្មារល្អតឲ្យមើលល្អី |
| វាល់ល្អកន្ទាំងបី | ទាន់ស្រូវថ្មីទារធាប់បាន។ |
| ជួនក្រែងឯងក្រវិញ | ទោះដូរទិញមើលប្រមាណ |
| ជឿបុលខ្ចីសន្ទាន | កុំហ៊ានពារកញ្ជើធំ។ |
| ខ្លួនក្រកំចង់ផាត់ | កុំងាកមាត់អាងតែសុំ |
| ជឿខ្ចីល្អីក្រមុំ | ស្រូវឯងទុំស្រណុកសង។ |
| បើជឿខ្ចីគេឲ្យ | កុំទៅញយគេឲ្យខ្នង |
| ឯណោះឯណោះផង | កុំច្រើនដងគេមើលងាយ។ |
| ក្រលុយកុំផុយដេក | ចូលដំណេកកុំនិយាយ |
| សំពត់ញាត់សំពាយ | រាយរើសរៀបញាត់សំពៀត។ |
| រៀបដេកសំពះគុណ | កុំដេកស៊ុនឲ្យប្រុងស្មៀត |
| ភ្លើងឆេះយប់អាធ្រាត្រ | កណ្តៀតទូលប្រមូលរត់។ |

ខ្ជួនរាស្ត្រក្រមាសប្រាក់ កើចកន្ទ្រាក់អាវសំពត់
ទំរាំភ្លើងរលត់ ស្មៀកផ្គង់ផ្គត់សោះខ្នាសគេ។
កូនអើយគិតឲ្យគ្រប់ រៀងរាល់យប់កុំទំនេរ
ដាំងដេកលក់ទទេ យល់សប្ដដេរបីសាចក្រៅ។
ទំលាប់មាត់មមើ ស្រែកថាយើៗ អៅៗ
ចោរខ្មាំងខ្មោចចិត្តខ្មៅ ហៅមេខ្មោវ៉ៃឲ្យខ្នុក ។
ដេកផ្តៀងដាំងអង្គុយ ល្ហាល្ហាន់ល្ហុយកុំទ្រាំផក់
ពីល្ងាចដេកពុំលក់ មាន់រងាវដក់ស៊ីម្ហូស្វា។
ដាំងល្ងឹតឥតអំពើ ឥតអ្វីធ្វើសូត្រធម៌អាថិ
បើច្បាស់វិបស្សនា ស្មាស្មាធស្មឹងប្រឹងឲ្យស្មោះ
គងខ្នើយដេកកើយស្នុគ្រ គ្របឲ្យសុខសូត្រអំបោះ
កុំដាក់ដោយកៀនកោះ អស់នឹងសត្វកណ្ដៀរកោរ។
កណ្ដុរកន្ធាតកាត់ ដល់កំណាត់ខានដេរខោ
ជួនកាលមានអាចោរ លលបលួចលីទៅបាត់។
កុំដាក់ឆ្ងាយប្រយោល ទុកជាចោលមិនប្រយ័ត្ន
ប្រយោជន៍យប់យាមស្ងាត់ បង្កាត់ភ្លើងបង្កោលគោ។
បង្ការក្រែងមូសខាំ ត្រូវចំណាំខ្យល់ដំនោរ
បាយកកផ្អកម្ហូបដោរ ឲ្យអាលោស៊ីចាំសេះ។
កំណើតឆ្កែញីឈ្មោល ដេកចំណូលតែនិងផេះ

រៀនប្រើមើលចំណោះ　　រិះចំណាំតាមកិរិយា។
ទោះប្រើកូនតូចធំ　　រីប្រើខ្ញុំឲ្យធ្វើការ
ធ្វើកលយល់ប្រាជ្ញា　　អាណាហ៊ានប្រើទៅឆ្ងាយ។
អាខ្លាចប្រើតែជិត　　ឥតគំនិតប្រើរឿងអាយ
ខុសម្ដងកុំជេរម្ដាយ　　ពេលដល់បាយកុំនាំឈ្លោះ។
មនុស្សឃ្លានវាហ៊ានឆ្លើយ　　ស៊ីរួចហើយបន្ទោសចុះ
បានឆ្អែតប៉ោងពេញពោះ　　ស្ដីខុសត្រូវមិនសូវខឹង។
កូនអើយពាក្យអាពុក　　ចំណាំទុកពីត្រឹមណឹង
ធ្វើប្រុសឲ្យខំប្រឹង　　រៀនឲ្យដឹងស្គាល់ពុតស្រី។
មារយាទនិងមាយា　　ម្យ៉ាងចិត្តជាចេះថ្នមប្ដី
ប្ដូរស្លាប់រស់វាហី　　យកពីរបីនេះមិនបាន។
កុំលោភច្រើនៗព្រួយ　　យកតែមួយសុខក្សេមក្សាន្ត
ចិត្តស្រីទាំងប៉ុន្មាន　　ហ៊ានប្រមូលម៉ៅមិនខុស។
មិនខូចគ្រប់តែស្រី　　ល្អពីបីចាំទុកចុះ
ជាតិស្រីលោកលើប្រុស　　នោះមិនខុសស្រីណាមួយ។
ខ្លាំងខ្សោយកុំឲ្យខ្សត់　　ទោះនឿតហត់កុំលំអួយ
ធ្វើប្រុសតែងតែព្រួយ　　ស្រីមិនជួយកុំត្អូញត្អែរ។
ខ្លួនខ្លាំងកុំគិតខ្លាច　　ស្រីៗកាចស្លូតដោយខែ
រដូវធ្វើស្រូវស្រែ　　ចែប៉ប្រែស្ដីលើប្រុស។

ខែស្ទូងនិងខែច្រូត		កាចរហូតដល់ខែបុស្ស
ខែបែនបោករលស់		រលីងអស់អំពីដី ។
ជញ្ជូនដាក់ជង្រុក		ពូជពេញទុកស្បោងពីរបី
ដំណើបបបួនដប់ល្អី		ស្រីៗស្ងួតហើយខែហ្នឹង។
ស្ងួតផុតនៅខែមាឃ		ស្តីធ្ងន់ពាក្យមិនសូវខឹង
បើប្រុសៗមិនដឹង		ប្រឹងតែព្រួតស្អប់ស្រីៗ។
ម្យ៉ាងទៀតមារយាទខូច		មាយាបេះក្រូចមាយាជកខ្ញី
មានប្រុសសហាយថ្មី		រឹតថ្នមប្តីមិនឲ្យអាក់។
អីអើតែមាត់ក្រៅ		ចិត្តមួម៉ៅគ្មានត្រជាក់
ត្រីសាច់ល្អលួចលាក់		ដាក់តែធ្អឹងឲ្យឯងស៊ី។
បញ្ឆោរចេះបញ្ឆើ		បញ្ឆោតប្រើឯងវក់វី
វរឹកព្រួតប្រុសពីរ		ស៊ីទាល់ផាប់គាប់សងខាង។
មួយទៀតផិតកំលោះ		ស្រលាញ់ស្មោះស្ម័គ្រអស់យ៉ាង
លោមប្តីលាសំណាង		ទាស់ក្អេងក្អាងទារសំបុត្រ។
បើប្តីមិនព្រមលែង		លបជំទែងជំទយរត់
មួយទៀតខូចបំផុត		មាត់ឲ្យប្រុសសំលាប់ប្តី។
ម្យ៉ាងទៀតមារយាទជា		មានច្រើនគ្នាក្នុងលោកិយ
ប្រាកដពេញជាស្រី		ប្រុសពីរបីស្នាលាកម្ម។
ស្លាប់រស់មួយនឹងមួយ		មិនចង់ព្រួយយកប្រុសប្រាំ

| | |
|---|---|
| ប្តីស្លាប់ប្អូនដប់ឆ្នាំ | ចាំសីលទានមិនមែនទៀត។ |
| ធ្វើបុណ្យផ្សងសច្ចា | សុំប្រាថ្នាជួបរាល់ជាតិ |
| អុចធូបដេកឱបជាតុ | កណ្តៀតថោកោរកាន់ទុក្ខ។ |
| និយាយពីពុតប្រុស | ចូរចាំចុះជាទំនុក |
| ដំណាតទៅមុខ | អាពុកប្រាប់ឲ្យស្រីចាំ។ |
| ប្រពន្ធមួយមិនស្កប់ | ប្រពន្ធដប់គ្រាន់តែស្កាំ |
| កាចស្លូតរហូតឆ្នាំ | រាំដរាបរាល់រូបា។ |
| កាចម្យ៉ាងខាងល្ងាចព្រឹក | រឿងបាយទឹកថ្នាំម្លូស្លា |
| កាចម្យ៉ាងខាងធ្វើការ | ម្យ៉ាងទៀតណារឿងប្រចណ្ឌ។ |
| ប្រជុំជាតិចិត្តប្រុស | ត្រូវនិងខុសជាកំណាន់ |
| គំនិតល្អសំខាន់ | ប្រកាន់មើលអិរិយាបថ។ |
| ប្រចណ្ឌរាវរាលឈ្មោះ | ច្រើនកើតឈ្មោះទៅជាខ្សត់ |
| មួយឃើញជាក់ប្រាកដ | ប្រកៀកចាប់ធ្វើទោសបាន។ |
| លកលៃតែខាងប្រុស | ប្រពន្ធខុសបង្អង់ខាន |
| ខូចម្តងខាតប៉ុន្មាន | រាប់អានឱបក្រសោបទៀត។ |
| មួយលកលៃទាំងពីរ | នៅរកស៊ីដោយសារញាតិ |
| ស្រីមាយាឥតមារយាទ | ស្មាលាជាតិមិនឲ្យជួន។ |
| ប្រចណ្ឌទាំងបីបទ | គួរគួចកត់ទុកក្នុងខ្លួន |
| លក់ពីរពេញចំនួន | គួនគុំទុកយកជាច្បាប់។ |

ប្រចណ្ឌហើយយកទៀត ហៅជួជាតិមារយាទអាប់
កូនណាយកតំរាប់ ស្ងាប់នឹងស្រីៗមើលងាយ។
ទោសតិចកុំទាញផ្សំ ឃើញមិនចំកុំនិយាយ
កុំចាប់ស្មើររើវាយ នាំឲ្យវល់អំពល់ចិត្ត។
ពុតប្រុសនិងពុតស្រី ចប់សេចក្ដីពីក្បត់ផិត
រៀងរើសណាសុខចិត្ត គិតសំគាល់រាល់រូបកាយ។
បើមានកូនក្រមុំ គួរតែកុំបណ្ដោយឆ្ងាយ
ឲ្យមើលនាយមើលអាយ ស្រេចនៅម្ដាយរក្សាកូន។
ប្រយ័ត្នកុំឲ្យឃ្លាត ភ្ជាត់មារយាទមិនសុទ្ធសូន្យ
កុំទុកចិត្តបងប្អូន ជីដូនមួយជួយរក្សា។
ក្រមុំមានម្រាក់មិត្រ មេមួយគិតនាំកិច្ចការ
កុំជឿចិត្តនរណា មើលកិរិយានៃកូនឯង។
ទោះស្ងួងជកយប់ថ្ងៃ ដើរយកដៃដាច់សង្វែង
ប្រុសខូចល្បួចបន្ទែង តែទាស់ភ្នែកបែកមេបា។
ច្រើនណាស់តែសែនខ្មោច កេរ្ដិ៍អាសោចផុតអាសា
នាំកូនឡើងសាលា គេថាឲ្យជំងឺចិត្ត។
បើមានកូនប្រុសា មិនទាន់ការគួរឲ្យប្រិត
កុំឲ្យបំរើផ្ដត អាណិតវាៗសងគុណ។
យប់ថ្ងៃចូលប្រតិបត្តិ គាតក្រវាត់រត់វែកពុន

| | |
|---|---|
| អាចនឹងច្រើនជឿមុន | ស៊ិនអំពីឪពុកម្តាយ។ |
| រក្សាកូនប្រពន្ធ | រកទ្រព្យធនចង់ធូរថាយ |
| ជួញជិតកុំជួញឆ្ងាយ | ជួញរៀងអាយរក្សាគុណា។ |
| អំពើបាបកុំរៀន | កុំអៀនប្រៀនក្នុងការបុណ្យ |
| លាងទោសចេញជាមុន | ទើបធ្វើបុណ្យចំរើនផល។ |
| បើនឹងចង់គង់ទ្រព្យ | កុំទំលាប់សាងអកុសល |
| របិញរបុញរៀចកាចកល់ | ទេវតាផ្តល់ផ្តាច់ធនធាន ។ |
| កុំឈ្នានិសអ្នកខ្សត់ | កុំបំភ្វាត់ទ្រព្យអ្នកមាន |
| បើខ្លួនខ្សត់អត់ឃ្វាន | រៀនតែរកតាមទៀងត្រង់។ |
| ជួញខាងកុំឈប់ខាន | បើចង់បានកុំខ្ជាចបង់ |
| ខ្ជាចបាត់ឲ្យផ្ចិតផ្ចង់ | ប្រុងថែទាំឲ្យមាំមួន។ |
| កុំភ្លើធ្វើជាភ្លេច | ភ្វាត់បន្តិចខ្ជាចក្រែងជួន |
| ក្រែងចោរចូលមកពួន | លួនលបលួចយកទ្រព្យទៅ។ |
| ប្រហែសតែងតែបាត់ | ប្រុងប្រយ័ត្នតែងតែនៅ |
| គិតសព្វគ្រប់ដោយផ្លូវ | សួរទ្រាំនឿយកុំទ្រាំក្រ។ |
| នៅផ្ទះស្រះរបង | របោចងឲ្យជាប់ល្អ |
| ប្រើប្រាស់ខ្ញុំកំដរ | ឲ្យបរិភោគដោយខ្លួនឯង។ |
| នឹងប្រើទៅហៅមក | កុំគំហកយកកំហែង |
| កុំហាឡើងហង់ឯង | ក្រែងកំហល់ទល់កំហឹង។ |

កុំហួសពាក្យសំដី
ការអ្វីៗឲ្យចេះថ្លឹង
កុំប្រើព្រួតលើប្រឹង
ក្រែងកើតខឹងវានាំខាត។
មនុស្សខឹងច្រើនៗខុស
មនុស្សច្រើនឈ្មោះច្រើនប្រមាថ
ការល្អច្រើនត្រូវខ្នាត
យើងចង់ស្អាតកុំខ្ជាចយូរ ។
ចង់ប្រាជ្ញឲ្យខំប្រឹង
ចង់ក្បិនតឹងរកស៊ីធូរ
គំនិតមុនគំនូរ
រៀនមានគ្រូមានគេរាប់ ។
បំរើឪពុកម្តាយ
អ្នកនៅឆ្ងាយគេច្រើនគាប់
អ្នកណាបំរើខ្ជាប់
ធ្លាប់តែខុសមិនដែលត្រូវ ។
ជាតិមនុស្សទោះខ្ពស់ទាប
មិនចោលភាពជាម៉ែឪ
ពាក្យមនុស្សវែងជាងផ្លូវ
ស្រូវច្រើនខួបខូចអង្ករ ។
របស់ទ្រព្យថោកថ្លៃ
ទុកសំចៃលៃឲ្យល្អ
អុងអាងពាងក្រឡ
ត្រដរទិញកុំឲ្យខ្វះ ។
កើតមកជាខ្លួនរាស្ត្រ
ក្រប្រាក់មាសឲ្យមានខ្មាស
សារពើគ្រឿងប្រើប្រាស់
ឲ្យមានចាស់ឲ្យមានថ្មី។
ពូថៅដឹងកាំបិត
ពន្លាកខ្វិតចបវែងខ្វី
ខ្សែរសេះគោក្របី
ឫស្សីផ្តៅកាច់សង្រែក។
ការងាយកុំឲ្យក្រ
អាក្រក់ល្អមានដោយឡែក
ថ្ងៃនេះរបេះបែក
ស្អែកខំរើធ្វើជាធាប់។
ឈ្មោះការប្រើលើដី
កុំចាំស្រីតឿនប្រើប្រាប់

ឲ្យមានគ្រប់ប្រដាប់ ដំរាប់រាល់ឲ្យសល់ប្រើ ។
កុំខ្ជិលល្ងង់ខ្លៅពេក ឲ្យចេះដេកឲ្យចេះដើរ
ចេះសព្វគ្រប់ប្រសើរ កុំចង់ហើរហួសភាពខ្លួន ។
ចង់ក្ដីឲ្យរៀនច្បាប់ រស់និងស្លាប់ឲ្យចេះក្បួន
ចេះអ្វីចេះឲ្យមួន កុំបន្ទំផ្សំនឹងគេ ។
កុំដេកចាំសំណាង កុំក្អេងក្អាងចាំបុព្វេ
ខំរកកុំទំនេរ រៀនរិះចេះឲ្យគ្រប់ ។
នឹងដើរស្វែងរកផល មិនទាន់ដល់កុំអាលឈប់
ឈានខ្លាំងពេកជំពប់ បើដេកយប់ឲ្យស្គាល់យាម។
កុំដេកយូរទ្រមឹក លក់ហួសព្រឹកខុសទំនៀម
តែក្ដីឡើងភ្ញាក់ភ្ញាម ព្រហាមឡើងក្រោកធ្វើការ ។
ជាតិមនុស្សទោះប្រុសស្រី រាស្រ្តមន្ត្រីជាធម្មតា
ពេលព្រឹកតែងអុស្សាហ៍ ថ្ងៃក្ដៅល្ហាខ្ជិលល្អូតធ្អឹង។
ចង់ធំខំពីតូច បើខ្វាចខ្វចកុំឆាប់ខឹង
ការអ្វីឲ្យចេះថ្លឹង កុំប្រឹងជុះតាមដំរី។
កុំចង់ខ្ពស់ស្មើមេឃ កុំឱនពេកអាប់រាសី
ទោះដើរនិយាយស្ដី លៃតែល្មមឲ្យគួរសម។
យល់ឆ្ងាយកុំណាយគិត ទោះយល់ជិតកុំអាលខំ
មិនជាក់មើលឲ្យចំ ក្រែងប្រទាំសជាខ្មៅ ។

ទំលាប់ធំជាងច្បាប់ បើរៀនត្រាប់កុំត្រាប់ខ្លៅ
ត្រាប់ប្រាជ្ញអាចប្រដៅ ស្តីកូនចៅស្តីឲ្យស្មោះ។
ស្មឹងស្មឹលសិល្ប៍របៀន ឲ្យគេរៀនកុំឲ្យអស់
ស្រលាញ់កុំញេះញ៉ោះ បើខឹងទាស់កុំឲ្យទាយ។
ផ្លែព្រុះកុំព្រួយពេក ឃើញផ្លែដេកកុំមើលងាយ
កំណាប់ដប់សំពាយ កុំនិយាយប្រាប់សម្លាញ់។
សំលឹងមើលឲ្យសព្វ បើនឹងស្អប់កុំអាលបាញ់
ក្តីឈ្នះគេចុះចាញ់ កុំក្នាញ់តាមផ្តន្ទាទៀត។
បើខឹងកុំរំលោភ បើនឹងល្មោភឲ្យល្មមមាឌ
កុំមាត់ក្រែងភ្ញាត់ស្មៀត វាតហួសវង់ផុតគំនិត។
កំណើតអាក្រក់ល្អ មាននិងក្រពីគំនិត
ពីកាលបុព្វពិត ងងឹតពេកមើលមិនយល់ ។
ដាំដូងឲ្យខំថែ ចង់ស៊ីផ្លែឲ្យដុតគល់
បើជួនសំណាងដល់ រលំតែស៊ីឆ្នាញ់ពិសា។
ប្រាជ្ញប្រិតប្រៀនប្រដៅ ចូរកូនចៅពិចារណា
រំពឹងក្នុងប្រាជ្ញា ស្រាយបញ្ហានេះឲ្យដឹង។
ចេះច្បាប់កេរកាលថ្មី អស់សេចក្តីតែប៉ុណ្ណឹង
កូនប្រុសអ្នកខំប្រឹង សំលឹងចាំតទៅមុខ ។
ពីឆ្នាំចតទៅ ខំធ្វើស្រូវដាក់ជង្រុក

អាសូរពាក្យអាពុក ទុកឲ្យកូនចៅគ្រប់គ្នា ។
អាពុកកាន់តែចាស់ ស្គាយខ្លួនណាស់ចូលជរា
ពាក្យពិតប្រាំរយឃ្លា ជាសូរេចម្ងេះឯងហោង។
អ្នកប្រាជ្ញកិរម្យល្បី លើច្បាប់ថ្មីអស់ល្បត់ល្បង
ឈ្មោះអូ ហៅ ង៉ុយផង ចងជាច្បាប់សំរាប់ជន ។
ខ្ញុំសូមផ្សងសច្ចា កើតជាតិណាសូមមានបុណ្យ
មូលកូនមូលប្រពន្ធ ធនសម្បត្តិសំបូរចាយ ។
ស្មាលាក្រលំបាក សូមជៀសចាកចតុរាបាយ
សូមល្អពង្សរូបកាយ កុំឲ្យឆ្ងាយពីព្រះពុទ្ធ ។
ប្រាជ្ញាកុំទើសទាស់ ចេះអាថិធម៌ឲ្យមាំមុត
សូមជាប់សីលបរិសុទ្ធ រលត់ទុក្ខសោករោគភ័យ ។
អានិសង្សបុណ្យខ្ញុំបាន សាងប៉ុន្មានក្នុងលោកិយ
សម្បត្តិសួគាល័យ កុំបីឃ្លាតវាតវែងឆ្ងាយ ។
ពីជាតិនេះទៅមុខ មូលអាពុកជួបមូលម្ដាយ
បងប្អូនកុំខ្ចាត់ខ្ចាយ អធិប្បាយចែងចប់អេវំ ។

# ច្បាប់ល្បើកថ្មី

អ្នកព្រះភិរម្យ ភាសាអ៊ូខ្ញុំ បង្ហំនឹកគុណ
ព្រះពុទ្ធព្រះធម៌ ព្រះសង្ឃជាមុន គុណគាប់មហាធ្ងន់
មាតាបិតា។

ឧបជ្ឈាយ៍ជាធំ កាលចាប់ដៃខ្ញុំ ឲ្យធម៌កេស
អនុសាវនេ ព្រះកម្មវាចា គុណតួអក្ខរា
ទាំងសាមសិបបី។

ខែចែត្រឆ្នាំច ចត្វាស័កក កគិតកាព្យថ្មី
លើច្បាប់ប្រដៅ កូនចៅប្រុសស្រី តូចក្តីធំក្តី
ចូរស្តាប់គ្រប់គ្នា។

ដ្បិតមនុស្សឥឡូវ យកខុសជាត្រូវ យកឆ្គួតធ្វើជា
អំពើអាក្រក់ ឡិកឡក់លីលា ព្រហើនពានពារ
អាងមាសអាងប្រាក់។

អាងព្រើលអាងប្រាជ្ញ អាងកោងអាងកាច អាងកាប់អាងចាក់
អាងជើងអាងដៃ អាងវាយអាងធាក់ អាងគុកច្រវាក់
អាងម៉ាស៊ីនកាត់ក។

អាងសុទ្ធតែខុស កូនអើយចាំចុះ អាងនោះមិនល្អ
អ្នកគិតឲ្យល្អិត ដ្បិតស្រុកលោកក្រ ប្រមាណតំណ
តទៀតទៅមុខ។

សាសនានៅឆ្ងាយ លែងបានសប្បាយ មានតែកើតទុក្ខ
កើតទាន់លោកីយ៍ លីតែទំនុក ដំណែលអាពុក

ចូរចាំគ្រប់គ្នា។

អ្នកជឿពាក្យចាស់ ជឿចាំឲ្យណាស់ កុំធ្វើបំពារ
អ្នកហ៊ានស្បែកដាច អ្នកខ្លាចស្បែកជា មនុស្សចោរប៉ោះបៀ
កុំយកខ្លួនបៀត។

ឃើញវិកគេល្អ ទោះបីមានក្រ យកគេជាញាតិ
គួររាប់អ្នកក្រៅ ជៅអ្នកឯទៀត រាប់រើសមារយាទ
សុចរិតត្រឹមត្រូវ។

រៀនបទរៀនបាទ កុំកោងហួសខ្នាត កុំភ្វាត់ខុសផ្លូវ
កុំភ្លើនភ្លេចម៉ែ កុំប្រែហួសឪ ឃើញចាស់សក់ស្កូវ
កុំសូវមើលងាយ។

បន្ទន់អាត្មា ខ្លាចមេខ្លាចបា ខ្លាចតាខ្លាចយាយ
បំរើមហាក្សត្រ ប្រយ័ត្នស្តេចទាយ ពាក្យពិតទំនាយ
រលាយកេរ្តិ៍ឈ្មោះ។

ពាក្យស្តេចពាក្យគ្រូ មានប្រែមានជូរ កំរពីរោះ
ជូនទាយឲ្យទាប ជូនទាយឲ្យខ្ពស់ ទាយឲ្យសក្តិយស
ទាញចុះកុំខឹង។

បំរើមើលភេទ ចំណាំព្រះនេត្រ ហេតុខ្លួនឲ្យដឹង
ខ្លួនខ្ចិលហៃព្រើល លោកមើលសំលឹង សំលក់ឲ្យប្រឹង
ខំប្រិតសូត្ររៀន។

បំរើមើលពុត ប្រាជ្ញាឲ្យមុត ស្មារតីឲ្យមាន
បើខ្លៅឲ្យប្រាជ្ញ បើខ្លាចឲ្យហ៊ាន ចង់បានរបៀន

កុំអៀនកុំខ្មាស។

ពុតលោកថាធំ ជ្រដោះប៉ុនភ្នំ ឯងមើលមិនច្បាស់
បំរើលោកណា លោកហ្នឹងជាម្ចាស់ លោកស្អប់អ្វីណាស់
ប្រាសចោលឲ្យឆ្ងាយ។

កុំឈមឈរជិត កុំយកធ្វើមិត្រ ភ្ជាត់ខ្លួនអន្តរាយ
បើប្រពន្ធកូន បងប្អូនចៅហ្វាយ អាពុកឬម្តាយ
ខិនកាយប្រតិបត្តិ។

អ្នកកុំមើលងាយ ឃើញគេរីករាយ ព្រួយខ្លួនប្រយ័ត្ន
ត្រកូលញាតិផៅ កូនចៅមហាក្សត្រ ស្មើថ្វើមប្រមាត់
ប្រមាថមិនបាន។

ទោះអ្នកដទៃ អ្នកព្រៀងអ្នកព្រៃ ដែលលោករាប់អាន
កុំថាតែមនុស្ស ទោះសត្វតិរិច្ឆាន ឯស្អប់មិនបាន
ជួយថែរក្សា។

របស់រីទ្រព្យ ដែលជាសំអប់ កុំបាច់សំអាត
ទ្រព្យណាសំលាញ់ អស់អញឱហាត ចូរចៅសង្វាត
ជួយថែរក្សា។

កុំជិះកុំជាន់ ស្មៅផ្ទីអាចម៍មាន់ ពាក្យចាស់ឱមា
បុរាណហៅផ្ទី ពីរបីប្រការ កុំស៊ីត្រង់ណា
ជុះដាក់ត្រង់ហ្នឹង។

សាច់សាលោហិត កុំផ្តួលផ្តេកផ្តិត ផ្តួចទោសកើតប្តឹង
អាពុកផ្តែផ្តាំ ចូរចាំចេះថ្លឹង សាច់ថ្លើមស្ងួតធ្នឹង

និងស្បែកខាងក្រៅ។

សាច់សួតក្នុងខ្លួន ទុកស្មើបងប្អូន ប្រពន្ធកូនចៅ
សរសៃនិងស្បែក ចែកជាញាតិផៅ ខ្ញុំស្រីខាងក្រៅ
ជាស្មៅអាច់មាន់។

ស្រីខ្ញុំកំដរ បើឃើញរូបល្អ កុំលលូកលាន់
កុំលួចលបលេង ក្រែងម្ចាស់គេទាន់ កុំកប់កុំកាន់
អាប់អន់អាត្មា។

បើអ្នកមានយស មានសក្តិខ្ពង់ខ្ពស់ គាប់នឹងរាជការ
ធ្វើធំធ្វើថី មន្ត្រីមានត្រា ព្រះហ្លួងឧកញ៉ា
សាលាកុង្សីយ៍។

ចេះច្បាប់បារាំង កុំភ្លេចសច្ចំ កតញ្ញូខន្តី
កុំផ្ទើងហួសមាឌ ភ្លេចញាតិប្រុសស្រី ជំនុំកាត់ក្តី
យកឧបេក្ខា។

កុំកាន់សីហលោ កុំកាន់លោភោ ទោសោមោហោ
កុំជក់អាភៀន កុំឃ្លានផឹកស្រា កុំស្អប់ត្រង់ណា
សច្ចាយកត្រង់។

ល្អងលោមពិសោធ កុំធបញ្ឆោត បញ្ចូលឲ្យបង់
ឲ្យបែកឲ្យបាក់ ពាក្យសត្យពាក្យសង្ឃ កូនអើយផ្ចិតផ្ចង់
តំរង់ស្មារតី។

កុំភ្លើនឃើញប្រាក់ កុំភ្លើភ្ញាត់សក្តិ ធ្លាក់ទៅអវចី
កាន់ធម៌ទសពិធ រីតឡើងរាសី គាប់ពីលោកិយ៍

ដល់បរលោកនាយ។

អ្នកក្តីជាភ្លើង កុំកាត់ជាន់ជើង អ្នកម្ខាងមើលងាយ
ចៅក្រមជាទឹក រលឹករំលាយ កុំដេរកុំវាយ
បង្ខំនាំខុស។

ចោរលួចចោរប្លន់ រីចោរស៊ីគ្រស្មន់ តណ្ហាស្រីប្រុស
កុំស្អប់ខាងណោះ បញ្ចេះខាងណោះ លួងលោមបញ្ចុះ
បញ្ចូលចិត្តក្តី។

កុំដុតឲ្យក្តៅ បើឃើញអ្នកខ្លៅ ប្រាជ្ញាគ្នាខ្ចី
កុំឃើញប្រាក់ប្រុស បន្ទុះខាងស្រី បើកាន់ច្បាប់ថ្មី
កុំចោលច្បាប់ចាស់។

កុំដៀលអ្នកស្រែ ត្រកូលឯងខ្មែរ កុំប្រែក្រលាស់
ក្រលេកមើលគុណ ទន់ខ្លួនសំពះ កុំធ្វើអ្នកណាស់
កុំត្មះអ្នកក្រ។

អ្នកកុំភ្លេចគុណ គ្រូលេខនព្វន្ត គ្រូសូត្រអក្សរ
កុំចាប់ដៃទាញ គំនាប់ងក់ក កុំជដៃកត
ស្មើមិត្តសំលាញ់។

វាស្រ្តរត់ចូលជ្រក សួរសាចទៅមក កុំអើឯងអញ
ពាក្យពុំពិរោះ គេកើតមួគ្នាញ់ គេដៀលផ្ចាលផ្ចាញ់
អន្តរាយកេរ្តិ៍ឈ្មោះ។

កុំឆ្មើងអាងបុណ្យ ស្រដីឲ្យទន់ ពោលពាក្យពិរោះ
ខ្លួនអ្នកនឹងថ្កើង នឹងឡើងសក្តិយស កុំធ្មៀតនាំឈ្មោះ

ញុះញង់អ្នកធំ។

កុំស្អប់អ្នកតូច បើឃើញគ្នាខូច គួរគិតប្រមុំ
ទោសគ្នាតិចតួច ផ្តួចឡើងជាធំ ផ្សែងពួតជាដុំ
ផ្តុំឆេះជាភ្លើង។

កុំភ្លើនភ្លេចខ្លួន ចេះសាសន៍ចិនយួន កុំចោលខ្មែរយើង
កុំធ្វើក្រអើត កុំពើតកុំពើង កុំពាក់ស្បែកជើង
ចូលវត្តលោកសង្ឃ។

ដោះមួកដាក់ឆ័ត្រ ឱនកាយប្រតិបត្តិ លំអុតឱនអង្គ
កុំស៊ីតាមឃ្លាន កុំហ៊ានតាមចង់ កាន់ច្បាប់ស្រុកហ្វង្ស
កុំបង់សាសនា។

កុំចង់ថ្កើងពេក កុំលើកដំណេក ហួសមេហួសបា
តែងខ្លួនឲ្យល្មម មើលពូជពង្សា សង្វេបនិដ្ឋិតា
រឿងផ្តប់បុណ្យសក្តិ។

បើទៅជាពស្ត្រ ប្រាជ្ញាវៃឈ្លាស គួរវាសធ្ងកធ្ងាក់
ឲ្យធ្មៀតរែកពុន បើធ្ងន់សុំដាក់ ខំរកមាសប្រាក់
ឲ្យគ្រាន់ទាន់ចាយ។

ពជ្យបារាំងសេស កួនកុំប្រហែស កុំថ្នមរូបកាយ
ដើរគិតដេកគិត ជួញជិតជួញឆ្ងាយ បើចង់សប្បាយ
ស្រេចនៅមានទ្រព្យ។

ពជ្យហ្វូងពីមុន រកស៊ីរែកពុន មានក្រតាមភ័ព្វ
ពជ្យលោកឥឡូវ ត្រូវខំឲ្យញាប់ តែខ្ជិលច្រើនជាប់

ខ្នោះជើងខ្នោះដៃ។

តាំងពីឆ្នាំច ចាំជាដំណ ទំនិញឡើងថ្លៃ
ចង់ក្បិតឲ្យតឹង ប្រឹងកុំសំចៃ សញ្ជឹងយប់ថ្ងៃ
កុំឲ្យក្រខ្សត់។

បើចង់ស្រាលខ្លួន រៀនសូត្រឲ្យមួន ឲ្យមាំឲ្យស្ទាត់
កុំចេះស្ទាក់ស្ទើ ល្ងីល្ងើឥតបទ បើចេះប្រាកដ
ប្រាក់រត់តាមហៅ។

កុំថ្នមកំលាំង កាប់ជីកចូកចាំង កុំថារង៉ាក្តៅ
រៀនអ្វីឲ្យឆ្អិន កុំឲ្យខ្ទោចឆៅ កុំដេកតែខ្ជៅ
ក្រក្រៅសន្តាប់។

បើលូង់ឲ្យចេះ រករៀនតំរិះ រិះរកតំរាប់
អិន្ទ្រីធ្វេងស្តាំ កុំចាំគេប្រាប់ រៀនស្តីរៀនស្តាប់
រៀនមើលឲ្យស្ពែង។

កើតមកជាមនុស្ស ទាំងស្រីទាំងប្រុស មិនដែលចេះឯង
បើក្រឲ្យមាន វិញ្ញាណចេះក្រែង គិតគ្រប់កន្ទែង
កុំដេកតែក្រ។

កុំប្លន់កុំលួច កុំខ្ជិលកុំខូច កុហកធូរធេ
បោកប្រាសយកប្រាក់ ប្រវ៉ាក់ជាប់ក កាន់មារយាទល្អ
សុច្ចរិតត្រឹមត្រូវ។

កូនអើយរកស៊ី កកាយធរណី ធ្វើស្រែយកស្រូវ
កុំតាមអ្នកណា បាតាមតែឪ លើកភ្ជីជិតផ្លូវ

កុំស្រាស់បន្ទា។

គេដើរយប់ថ្ងៃ មុតជើងមុតដៃ ដឹងចៀសទៅណា

ចៀសចុះដាន់ស្រូវ ហើយដេរផ្កាសា កូនម្ដាយអាណា

ស្រាស់ដើរមិនរួច។

កុំយកគល់ឈើ ទៅដាក់ពីលើ ទោះធំទោះតូច

ជំពប់ជើងគេ គេថាឯងខូច ដេរដៀលដល់ពូជ

ប្រដូចមេបា។

លើកភ្លឺឲ្យធំ បផ្ទាប់ឲ្យមាំ គាប់ភ្នែកទេវតា

ស្មើបានសង់ស្ពាន នឹងមិនផលា កើតសាធុការ

អាយុយឺនវែង។

កូនអើយធរណី បើតាមគម្ពីរ ដែលលោកសំដែង

កុំចង់បានធំ ក្រមុំឆ្វេលឆ្វែង កុំលើកដីឯង

លបដាក់ស្រែគេ។

អំពើអាក្រក់ មួយចំរៀកសក់ ធ្លាក់ទៅនិរយេ

បច្ចុប្បន្នលោកិយ៍ កើតក្ដីវាយដេរ មិនដែលសុខទេ

ព្រោះដីមួយហត្ថ។

កុំជួញចង់ទាស់ ខូចខាតរបស់ អស់ទ្រព្យសម្បត្តិ

ចង់គង់ប្រយោជន៍ ឲ្យបេះប្រយ័ត្ន ពាក្យឪមួយមាត់

ឲ្យគិតមួយម៉ោង។

សំអាតផ្ទិតផ្ទង់ លើកភ្លឺឲ្យត្រង់ កុំលើកឲ្យកោង

អ្នកកុំប្រហែស ក្រែងមានប្រហោង លើកមើលទំនង

ទំនាបទឹកហូរ។

ចំនួនទឹកស្ទឹង ទឹកព្រែកទឹកបឹង ទឹកវាលទឹកអូរ
អ្នកលើលិចស្រូវ ត្រូវបើកបង្ហូរ អ្នកក្រោមកុំថ្ងូរ
បន្ទូរហួសទៅ។

ពាំងរឹងថ្ងៃយប់ កុំឲ្យបាក់ជ្រៅ ឆាប់លើកឆាប់ទប់
កត្តឹកបេញខ្យល់ តំកល់ទឹកនៅ បើចង់បានស្រូវ
ស្រេចនៅត្រឹមថៃ។

កុំយកគ្រាប់ត្នោត ទៅដាំទៅដោត ពីលើភ្លឺស្រែ
ចិត្តគិតប្រមាណ ចង់បានផ្កាផ្លែ ដាំដុះដង្ហែ
បង្កិនខ្លួនឯង។

ដល់ត្នោតឡើងគល់ ឡើងកើតនាំខ្វល់ ធាងលូតឡើងវែង
ភ្ជួររាស់ជាប់នឹម ក្របីជាប់ស្នែង ទទើសទទែង
ភ្ជួរឆ្វេងមិនត្រូវ។

ដល់ត្នោតវាធំ មានស្លឹកវាទុំ វាជ្រុះក្នុងស្រូវ
ស្រែឆ្ងាយពីផ្ទះ ឃ្លាតណាស់ពីផ្លូវ ទំរាំតែទៅ
រលួយស្រូវអស់។

កូនអើយកុំឆោត បើចង់បានត្នោត ដាំដោយកៀនកោះ
ដីទួលចំការ ឯណាចន្លោះ ដាំជារបស់
ជាយជួររបង។

របៀបចំការ ថែទាំរក្សា យូរៗស្រាស់ម្ដង
ស្រាស់ឲ្យត្រូវជួរ មើលគួរសមផង កុំបើកមុជឆ្វង

ទៅស្រាស់ខាងក្រៅ។

មិនគាប់ប្រសើរ   របងវាដើរ   អ្នកម្ខាងវាក្តៅ
កើតក្តីកើតក្តាំ   អស់ខោអស់អាវ   ខឹងអស់ញាតិផៅ
ពីព្រោះចំការ។

មួយទៀតរបង   ជិតផ្លូវអ្នកផង   គេទៅណាៗ
ធ្វើឲ្យទូលាយ   កុំពាយបន្ទា   កាប់ឆ្កេះទាត់ធ្លារ
ឲ្យឆ្ងាយពីផ្លូវ។

កុំធ្វើចង្អៀត   ក្រែងយប់អាធ្រាត្រ   ខ្លះមកខ្លះទៅ
ចៀសគ្នាមិនរួច   បើកបរកាត់ស្រូវ   ជេរម្តាយតាមផ្លូវ
រហូតដល់ផ្ទះ។

កូនអើយអ្នកចាំ   អ្នកកុំចង់កម្ម   មានពៀរច្រើនណាស់
ជាតិក្រោយខ្វក់ខ្វិន   កខ្វះកខ្វាស   សូវចោលដីខ្វះ
មិនខាតប៉ុន្មាន។

កុំខ្វាចតែក្រ   ធ្វើរិកមិនល្អ   ច្រើនកើតវឱស្ថាន
រអែករអោក   បាត់ញាតិសន្តាន   ឥតគេរាប់អាន
មានតែគេស្អប់។

កាន់រិកឲ្យខ្ពស់   ឲ្យខ្ពើមពាក្យឈ្មោះ   ទើបបានជាគាប់
យកឆោតដាក់ខ្លួន   ច្រើនមានគេរាប់   បើខ្លួនឥតទ្រព្យ
កុំធ្លាប់ហ៊ានខ្ចី។

គ្រប់ការសារពើ   ចង្អេរកញ្ជើ   កន្ទាំងតៅល្អី
រនាស់រទេះ   គោសេះក្របី   បើបានជាខ្ចី

ខ្ចីប្រាក់គេទិញ។

| | | |
|---|---|---|
| យកមករកស៊ី | ខែមួយខែពីរ | សងប្រាក់គេវិញ |
| របស់បានយើង | ជាដើមជួញចេញ | ឯទ្រព្យនោះមិញ |
| | ពេញជាទ្រព្យឯង។ | |
| កុំខ្ចីគេប្រើ | តែមួយដំណើរ | មិនយូរអង្វែង |
| ជូនជាបាក់បែក | ជដែកទាស់ទែង | សងគេមិនលែង |
| | ចាស់ផ្លាស់ជាថ្មី។ | |
| កើតមកជាប្រុស | គិតឲ្យសព្វសុស | កុំឲ្យសល់អ្វី |
| បួសរៀនធម៌អាថិ | សាស្ត្រាបាលី | បរលោកលោកិយ |
| | កុំបីចន្ទោះ។ | |
| សឹកមករកស៊ី | កកាយធរណី | ធ្វើជាគ្រហស្ថ |
| កុហកជឿបុល | បំណុលរុំកោះ | ច្រើនគេដាក់ខ្នោះ |
| | អស់ស្រែចំការ។ | |
| ធ្វើរាស្ត្ររកស៊ី | ចិញ្ចឹមគោញី | ថែទាំព្យាបាល |
| ក្រហេតុពីខ្ជិល | មានត្បិតអុស្សាហ៍ | អ្នកមានប្រាជ្ញា |
| | មិនស្មើគំនិត។ | |
| កំណើតសំណាង | សំណូមសូមសាង | កកើតពីគិត |
| ពីកាលជាតិមុន | បុណ្យព្រេងអតិត | កើតរូបគំនិត |
| | ទើបកើតសំណាង។ | |
| ឯមនុស្សសំណល់ | ល្ងង់ល្ងើឡើងឆ្ងល់ | ទាស់ទែងក្អេងក្អាង |
| ដប់ឆ្នាំនេះហើយ | ប្រកាន់ម្យ៉ាងៗ | ខ្វះអួតសំណាង |

ខ្វះអាងគំនិត។

កូនចៅប្រុសស្រី រកប្រពន្ធប្ដី ឲ្យរកស្រុកជិត
បើរកស្រុកឆ្ងាយ ឲ្យម្ដាយពិនិត្យ ឲ្យត្រឹមត្រូវពិត
ពូជពង្សរាវតារ។

កូនអើយអ្នកចាំ កុំជឿខែឆ្នាំ កុំជឿតំរា
ពាក្យក្បួនទាំងឡាយ កើតពីមនុស្សចារ ពីដូនពីតា
ចារតាមសំគាល់។

អ្នកជឿតែពូជ អំបូរធ្លាប់ខូច វាខូចពងពាល់
ពូជមានវាមាន ពូជទាល់វាទល់ កុសលអកុសល
យើងមើលមិនដាក់។

ប្រពន្ធនិងប្ដី អាយុវែងខ្លី យើងមើលមិនច្បាស់
កុំយកពូជល្បែង ពូជក្មេងអារក្ខ បើម៉ែបង់ប្រាក់
រកអាយុវែង។

អំបូរពង្សពូជ ត្រកូលធ្លាប់ខូច វាខូចមិនលែង
ពូជចោរស្រីៗ យកប្ដីចិត្តឯង មិនគិតកោតក្រែង
ខ្វាចចិត្តមេបា។

កូនចៅស្រីៗ បើនឹងយកប្ដី ឲ្យមើលកិរិយា
មួយក្មេងអារក្ខ មួយអ្នកបាណា មួយអ្នកផឹកស្រា
មួយអ្នកចង់ស្រី។

មួយអ្នកក្រមាច់ លេងផោមលេងអាច់ ច្រើនអាយុខ្លី
ប្រកាច់ដាច់លក្ខណ៍ ជាន់អារក្ខព្រៃ មួយគឺមន្ត្រី

ធ្វើក្រមជំទប់។

ជំទយតែដើរ មេស្រុកគេប្រើ ទាំងថ្ងៃទាំងយប់
មានមួកខ្វះឆ័ត្រ កំរមានគ្រប់ មួយទៀតកុំភប់
ដួញប្រាំប្រការ។

ប្រាកដជាខុស លក់សត្វទាំងរស់ មិនបេះអនិច្ចា
សព្វសត្វអ្វីៗ បក្សីបក្សា ព្រាត់មេព្រាត់បា
ទេវតាលោកលក់។

លោកិយនេះខ្សត់ យម្ពបាលគេកត់ នៅស្ថានរក
មួយហួយអាប៉ោង ប៉ោបៀគ្រប់មុខ កូនអើយចាំទុក
ក្រគ្រប់ប្រាំបី។

ឯអ្នកទាំងអស់ រកស៊ីម៉េះម៉ស់ ច្រើនជាងស្រីៗ
ប្រាជ្ញានោះវែង គំនិតនោះខ្លី ប្រពន្ធជេរស្តី
អាងឈ្មោះបំពាន។

នេះពូជអ្នកក្រ រស់ទាំងត្រដរ ទាំងអត់ទាំងឃ្លាន
ធ្វើគុណនឹងគេ រកគេសងគ្មាន ហេតុនេះកុំរៀន
ទាំងប្រាំបីផ្លូវ។

យ៉ាងអ្នកនេសាទ មិនដែលសង្វាត ធ្វើស្រែបានស្រូវ
ប្រព្រឹត្តសាងកម្ម ប្រចាំរដូវ វង្វេងខុសត្រូវ
ព្យាយាមសំលាប់។

អន្ទាក់ជង់កុក អង្រុតឈ្នាងឈ្នក់ គ្រប់គ្រឿងប្រដាប់
ថ្នុកបៀត្រពាំង ទប់បាំងបាចចាប់ ចោលស្រូវកណ្តាប់

កណ្តុរកាត់អស់ៗ

កំពប់ខ្នាត់ខ្នាយ ខូចខាតអន្តរាយ មិនស្តាយស្រណោះ
យប់រវល់ប្របក់ ចង់បានត្រីរស់ ខែភ្ជីរវល់ធ្ចុះ
ដើរដេញសំពោច។

វក់តែសប្បាយ ដើរដេញទន្សាយ ដើរចងសន្ទូច
អំពើអស់នោះ ច្រើនខ្វះស្រូវពូជ ធ្វើបានតិចតួច
អាងជឿគេស៊ី។

កូនអើយបំណុល ចង់ការជឿបុល មួយឡើងជាពីរ
អ្នកក្មេងអារក្ខ ច្រើនទឹមគោញី ធ្វើស្រែមួយពីរ
ធ្វើសោះតែខាន។

ថ្ងៃដេកក្រភ្នាក់ យប់លៀងអារក្ខ ឈឺផ្អាលសន្តាន
គេស្តីគេពឹង នឹងឈប់មិនបាន គេរករាប់អាន
កាលមានធុរៈ។

ផ្ទុំប៉ីកូតទ្រ ស្រែកច្រៀងវាយស្គរ មិនបានលុយកាក់
ឯងពឹងគេវិញ គេគ្មានជំពាក់ ពឹងបានម្នាក់ៗ
ដោយសារឲ្យថ្លៃ។

ឡើងត្នោតក្ទួរស្រែ កំរទាន់គេ ដ្បិតដេកដល់ថ្ងៃ
ប្រូតកាត់ចង់ធាប់ ជួលគេពេញថ្ងៃ ចំណោះចង្រៃ
នាំខាតធ្វើការ។

ឯខ្មោចអារក្ខ ស្លាប់ដប់រស់ម្នាក់ ថ្វាយចេកថ្វាយស្រា
សំពះនឹកគុណ ខ្មោចប្រេតជូនតា មិនដែលអ្នកណា

នឹកគុណអ្នកភ្លេង។

ឯអ្នកប្រមឹក ប្រមូលកនផឹក ធ្វើភឿននឹងភ្លេង
សំដីច្រើនតឹង ស្រវឹងវង្វេង ចំហរអួតក្អេង
មិនចេះក្រខ្សត់។

អួតទាំងបំពាន ផឹកម៉្វែលុយមាន ផឹកម៉្វែលុយអត់
ឯងចេះតែកិន ចិនគិតតែកត់ ផឹកដល់កំណត់
យកស្រែបញ្ចាំ។

សល់ថ្នាលមួយពីរ វាយគោស្ទោរស៊ី មិនគិតខ្វាចកម្ម
ផឹកជ្រុលហួសល្បត់ អត់បាយរាប់ឆ្នាំ អស់ស្រែបញ្ចាំ
បញ្ចាំកូនទៀត។

កំណើតផឹកស្រា ផឹកផុតមេត្តា ផឹកជ្រុលហួសមាឌ
អ្នកមួយផឹកស្ទើរ ល្ងីល្ងើចេះធ្មៀត ម្យ៉ាងផឹកផុតមារយាទ
ច្រើននៅខ្ញុំចិន។

វែកទឹកពុះអុស វាទុញវាតុះ ចាក់កែវផឹកសិន
ស្ទូវែកខំអត់ សំពត់ខើចក្បិន ទំរាំបាយឆ្អិន
ចិនដួសហៅស៊ី។

ឆ្ងាញ់តែម្នាក់ឯង ឆ្អែតហើយខំស្វែង ខំលើកខំលី
ដងទឹកស្រោចគ្រប់ ស្រោចខ្ទឹមម្ទេសជី ខ្ញុំចិនម៉្វែពីរ
វិលទៅរាំងផ្ទះ។

ឯអ្នកចង់ស្រី ប្រពន្ធពីរបី ថាឯងអ្នកណាស់
គន់ឯសំពត់ តែមួយបន្ទាស់ ពាក់អាវបំណាស់

កំរមានថ្មី។

ផ្ទះលេចវាលល្វឹង ជញ្ជាំងចង់ហ៊ឹង ស្វាធ័របាយសី
ខ្ជួចប្រេងក្រមួន ម្ជូស្វាបារី កំលោះពីរបី
ចោមពោមរៀនស្នេហ៍។

រៀនស្នាលរៀនស្និទ្ធ កើតក្តីពីក្តិត ព្រួយចិត្តម៉ែឪ
កូនអើយប្រពន្ធ អាងមន្តពូកែ ត្រូវគុករាប់ខែ
អស់ស្រែត្រពាំង។

ជម្ទាប្រពន្ធ បានដោយសីលមន្ត ដោយស្វាត់កំបាំង
រកស៊ីលៀនភ្នែក បានវែកខ្វះផ្ទាំង បានល្អីកន្ទាំង
នៅខ្វះចង្អើរ។

បាននេះខ្វះនោះ ក្រហេតុពីព្រោះ អាពុកម្តាយជេរ
បើចូលជំនុំ មិនរម្យដូចគេ អង្គុយវេះវេរ
មិនហ៊ានហាលមុខ។

នេះពុតអ្នកក្រ ចាំជាតំណា តជាទំនុក
ប្រយ័ត្នដំនៀល គេដៀលអាពុក កូនអើយចាំទុក
ចាំតកូនចៅ។

រក្សាពូជពង្ស បើខ្លួនល្ងឹតល្ងង់ ស្តាប់ចាស់ប្រដៅ
កុំស្អប់អ្នកប្រាជ្ញ កុំខ្លាចអ្នកខ្លៅ បើមនុស្សឆោតឆៅ
កូនឯងកុំភប់។

កុំភ័យខ្លាចអត់ មើលឲ្យប្រាកដ គួរយកគួរឈប់
គួរឈានគួរឈោង តោងមើលឲ្យគ្រប់ កុំចេះតែងប់

មិនស្តាប់ឪម៉ែ។

រកប្តីប្រពន្ធ ឲ្យគិតឲ្យគន់ ឲ្យមើលជូនថៃ

ត្រកូលក្រខ្សត់ ប្រាកដតាមខ្សែ បីដូចឈើផ្លែ

មិនដែលចេះក្លាយ។

ដូរផ្អែមធំតូច ដើមក្រូចផ្លែក្រូច ដើមស្វាយផ្លែស្វាយ

ពូជស្រីចោរក្បត់ មិនអត់សាហាយ ពូជស្រីមេម៉ាយ

ពីម្តាយដល់កូន។

រើសពូជមិនខុស ពូជសាំងនិងប្រុស ទាំងអស់បងប្អូន

ពូជសែនមេបា ពីតាដល់ដូន ពូជល្អសុទ្ធសូន្យ

ពីដូនដល់ចៅ។

រករូបមិនក្រ អាក្រក់ហើយស មារយាទល្អហើយខ្មៅ

ស្រីក្មេងមានខ្មាស ប្រដូចតាមដៅ ចាស់ចង់ប្រដៅ

មិនសូវខុសខាន។

ពាក្យចាស់លោកថា ធ្វើស្រែចំការ ស្តាប់មហាសង្ក្រាន្ត

ធ្វើម្តងខុសខាត ធ្វើម្តងទៀតបាន ធ្វើតាមប្រមាណ

ប្រមើលទឹកភ្លៀង។

រកប្តីប្រពន្ធ ឲ្យគយឲ្យគន់ រើសរករូបរាង

ពូជថ្លៃល្អមយក ពូជថោកល្អមរាង រូបល្អរិកល្អៀង

នាងកុំប្រសព្វ។

ជាតិស្រីនិងប្រុស បើបានជាខុស ខុសទាល់ថ្ងៃងាប់

បើបានរូបល្អ កំរមានភ័ព្វ មានខុសមានគាប់

ដូចស្រែចំការ។

មួយទៀតអ្នកចាំ អាពុកចំណាំ ទុកជាតំរា
កុំយកតំរាប់ កុំស្តាប់អាចារ្យ បើនឹងរៀបការ
កុំការប្រធូន។

ប្រដែងវេលា លឺស្គរធ្វើយគ្នា ប្រទប់ប្រទូន
ស្រុកជិតភូមិផង របងដោយខ្លួន អាចារ្យអាងក្បួន
ជាសុខសប្បាយ។

កូនអើយអ្នកចាំ យូរណាស់៤ឆ្នាំ ព្រាត់ប្រាស់អន្តរាយ
ច្រើនស្លាប់បីនាក់ រស់ម្នាក់មេម៉ាយ កូនឃើញតែម្តាយ
មិនឃើញអាពុក។

មានកាលស្លាប់ស្រី ស្លាប់ចោលកូនខ្ចី ប្តីនៅរងទុក្ខ
យកប្រពន្ធទៀត កំរពេញមុខ កូននិងអាពុក
បែកគ្នាខ្វាត់ខ្វាយ។

កូនចៅស្រីៗ បើនឹងយកប្តី កុំយកពោះម៉ាយ
សូវនៅម្នាក់ឯង បន្ទែងនឹងម្តាយ អាណិតរូបកាយ
ស្តាយខ្លួនក្រមុំ។

ហៅប្រុសអក័ព្វ ប្រពន្ធដើមស្លាប់ មានកូនតូចធំ
យកឯងជាចុង បំរុងតែឃំ ច្រើនឈ្មោះជំនុំ
ព្រួយចិត្តម៉ែឪ។

ហៅប្រុសចិត្តពីរ ពិបាករកស៊ី រញ៉ាំរញ៉ូវ
ឯងនឿយស្ទើរស្លាប់ ផ្គាប់ចិត្តមិនត្រូវ បីបួនរដូវ

ខ្លួនឯងស្លាប់ទៀត។

ចង្រៃខាងប្រុស កូនអើយចាំចុះ កុំយកខ្លួនបៀត
ស្រីណាខំយក ស្រីនោះបង់មារយាទ ប្រុសព្រួយខ្ទប់ជាតុ
ខ្ទប់គ្រប់ជាបី។

យកទៀតជាប្អូន គ្រោះដល់ស្លាប់ខ្លួន មេម៉ាយខាងស្រី
ប្រាកដមិនខុស ប្រុសក្នុងលោកិយ ស៊ូនៅអត់ប្តី
ស្លាប់រស់រូបមួយ។

បើខ្លួនកំព្រា រំពឹងមីងមា រកស៊ីមិនព្រួយ
កាន់មារយាទល្អ មិនគ្រគេជួយ បងប្អូនកូនក្មួយ
រត់ចូលឲ្យប្រើ។

ពោះម៉ាយមានបី កុំយកធ្វើប្តី មិនគាប់ប្រសើរ
អាមួយស្រីលែង ស្រីគេគ្រាន់បើ ពោះម៉ាយក្វាយដើរ
អាងលែងប្រពន្ធ។

ពោះម៉ាយទាំងអស់ កុំយកឲ្យសោះ ហៅប្រុសទូរជន
ទូរជាតិអប្រិយ ស្រីកើតទុក្ខធ្ងន់ ហៅមួយជំនាន់
ចំណាំមិនខុស។

កំលោះចាស់យូរ ចាស់ទុំគេប្តូរ ល្មមព្រមយកចុះ
រកស៊ីមានបាន សុខសាន្តឥតឈ្លោះ ចំរើនរូបរស់
អាយុយឺនយូរ។

កុំយកប្តីប្អូន ជោកពាសីខ្លួន រកស៊ីមិនធូរ
គេហៅឯងធំ សមហៅគេតូច ច្រើនខ្ជិលមូទូ

ម៉ែះម៉ស់នឹងល្បែង។

វាច្រើនមើលងាយ ហៅស្ដីនិយាយ ហៅហង់ហៅឯង
ខ្លួនយើងជាស្រី ស្រដីឥតក្រែង យល់គេប្អូនឯង
ឯងមើលងាយដេរ។

ពាក្យចាស់លោកចង់ ប្ដីទុកស្មើបង ប្រពន្ធស្មើម៉ែ
មើលងាយរាល់ថ្ងៃ ចង្រៃរាល់ខែ រកស៊ីធ្វើស្រែ
ច្រើនខាតគ្រាប់ស្រូវ។

គួរយកប្ដីបង ពាក្យចាស់លោកចង់ ទុកប្ដីស្មើឪ
ខ្លួនឯងប្រមាថ ប្រតិបត្តិឲ្យត្រូវ វាសីគង់នៅ
ទេព្រិក្សរក្សា។

ប្រពន្ធនិងប្ដី ធំស្រេចនឹងស្រី គត់គង់ករិយា
ឈ្មោះហើយច្រើនខ្សត់ ស្រីអត់លក្ខិណា ប្ដីខ្ជិលអុស្សាហ៍
ព្រោះវិកប្រពន្ធ។

ជាតិស្រីមានលក្ខណ៍ ទេវតាពុំនាក់ កបកើតទ្រព្យធន
ប្រទេចដេរវាយ ចង្រៃទូរជន ជួរជាតិលើសលន់
លើសលុបលើប្រុស។

ហៅកាឡកិណី វាយកូនដេរស្ដី មិនដឹងត្រូវខុស
បើមានភ្ញៀវមក រឹតរករឿងឈ្មោះ អសោចសាយសុស
រង្គោះធនជាន។

រកស្រីមារយាទខ្ពស់ ចេះខ្លើមពាក្យឈ្មោះ ចេះទ្រាំអត់ឃ្លាន
ចេះស្ងួតចេះកាច ចេះខ្វាចចេះហ៊ាន ចេះខ្មាសចេះអៀន

កាចមានប្រាជ្ញា។

កូនចៅស្រីប្រុស ចំណាំទុកចុះ ទុកជាតំរា
គួរយកតំរាប់ គួរស្តាប់ពុទ្ធដិកា ព្រះអង្គទេសនា
គាថាបួនបទ។

រៀនគ្រាប់អ្នកប្រាជ្ញ បើចង់ឈ្នះកាច យកស្លូតសង្កាត់
ចង់ឈ្នះមនុស្សខឹង ឲ្យប្រឹងខំអត់ វាដេរវាហត់
វាស្បថលែងខឹង។

ចង់ឈ្នះអសុរោះ ស្តីលេងឡេះឡោះ កុំធ្វើជាដឹង
យើងស្តីត្រង់ណា ឲ្យចំត្រង់ហ្នឹង ឃើញរិកយើងរឹង
ខ្លាចយើងខាងក្រោយ។

ចង់ឈ្នះកំណាញ់ ក្រដេក្រដាញ់ សុំអ្វីមិនឲ្យ
បើបានចំណី ហុចវាញយៗ តិចដោយច្រើនដោយ
ក្នុងតែវាដឹង។

នេះមន្តព្រះពុទ្ធ ប្រាជ្ញាឲ្យមុត ឲ្យគិតថ្លៃថ្លឹង
កុំកាចខុសខ្នាត កើតខាតដ្បិតខឹង កូនអើយខំប្រឹង
កាន់ច្បាប់ទាំងបួន។

កុំជួញវល់ កុំតបតទល់ កើតទាស់គុំគួន
កូនណាកាន់បាន កូននោះសុខខ្លួន ទោសទាស់លែងជួន
លែងជួបមួយជាតិ។

បើមនុស្សរែកទូល មកនៅចំណួល ញ៉េះញ៉ាស់ធ្វើញាតិ
ឲ្យមើលលៃលក កុំយកខ្លួនបៀត វាទូលទៅទៀត

អសារឥតការ។

ចំណីចំណុក បើឲ្យស៊ីចុក ឲ្យដោយមេត្តា
កុំឲ្យជឿខ្ចី ក្រែងខុសសន្យា កើតទាស់កាលណា
រើរែករត់បាត់។

មនុស្សគ្មានកន្ទែង ខុសពីមារយាទឯង មិនប្រុងប្រយ័ត្ន
តាមទាន់តឹងទារ វាខឹងក្តៅក្តាត់ គុំគួនដោយស្វាត់
បំភ្លាត់ឯងបាន។

ហេតុនេះគួរគិត គួរកូនពិនិត្យ ច្បាស់សុំរាប់អាន
គួរឲ្យសុំឲ្យ គួរខានឲ្យខាន ត្បិតពាក្យបុរាណ
មានពីរចំណែក។

ចងទុកជាក្បួន ចិត្តល្អក្រខ្លួន នេះពាក្យមួយប៉ែក
មួយទៀតចិត្តល្អ មិនក្រយូរពេក ឆ្នាំនេះឆ្នាំ(ស្អែក?)
ក្នុងតែនឹងមាន។

ចិត្តល្អក្រខ្លួន ចាំទុកជាក្បួន ជាក្បាលនិទាន
ឃើញអ្នកទុរគត កំសត់អត់ឃ្លាន មិនស្គាល់ពោះវៀន
ហ៊ានឲ្យជឿខ្ចី។

ទៅទារមិនឲ្យ តឹងតឿនញយៗ ខឹងប្តឹងកើតក្តី
ខាតទាំងទ្រព្យចាស់ អស់ទាំងទ្រព្យថ្មី ស្គមគោក្របី
រវល់ក្តីខាន់ថៃ។

ចិត្តល្អមួយទៀត មេត្រីជាញាតិ សំដីខ្ចីស្រែ
បានស្រូវស៊ីស្កប់ ត្រលប់កាច់កែ រំលងឆ្នាំខែ

ដកហូតមិនបាន។

ឯងប្តីឯងវា ត ក្តីទាល់តែក្រ អស់ផ្ទាំងអស់ថាន
របស់ក៏ខាត របរក៏ខាន ដីឯងអស់ប៉ុន្មាន
ទំពាំចាញ់ឈ្នះ។

ទ្រព្យធនអ្វីៗ ចងការជឿខ្ចី មើលមុខឲ្យច្បាស់
កុំចោលច្បាប់ខ្មែរ កុំភ្លេចច្បាប់ព្រះ តាមតែប្រទះ
ប្រទាញសងខាង។

ចាំចិត្តកណ្តាល បើនឹងឈើឆ្កាល សប្បុរសមើលយ៉ាង
រៀនសូត្ររៀនប្រាជ្ញ កាចកុំភ្លេងភ្លាង ក្រែងគ្រោះសំណាង
ខ្មោចខាងវាស្អប់។

ល្អមិនក្រយូរ ស្វែងរៀនរកគ្រូ ស៊ូកុំស្តាយទ្រព្យ
គ្រូវាយកុំខឹង ឲ្យប្រឹងខំផ្ចាប់ ចេះមន្តសាយសព្វ
ត្រលប់ជាមាន។

ធម្មតាអ្នកចេះ អ្នកស្វែងចំណេះ ចេះដ្បិតខំរៀន
ធ្លាក់គួរក្បូរក្បាច់ សាច់សិល្ប៍របៀន អ្នកខ្សត់អត់ឃ្លាន
ព្រោះចិត្តអាក្រក់។

ខូចខិលល្ងង់ខ្លៅ គ្រូដេរប្រដៅ ខឹងលបសំលក់
របេញរបុញ ភូតភរកុហក ស៊ូប្លន់លួចឆក់
មិនខំធ្វើស្រែ។

អ្នកប្លន់អ្នកលួច ឆក់បានតិចតួច បានគ្រាន់បើដែរ
ដល់គេឃើញមុខ ត្រូវគុកច្រើនខែ អាក្រក់ដល់ម៉ែ

ខូចកេរ្តិ៍ដល់ឪ។

ចង់ខ្ពស់បានទាប ចបើងចង់លាភ វែងបាត់ធនទៅ

ពាក្យពីបូរាណ លោកអានតំរូវ រិកមនុស្សឥឡូវ

ត្រូវតាមតំរាយ។

អ្នកលួចអ្នកប្លន់ ចង់បានប្រពន្ធ ចេញជួញស្រុកឆ្ងាយ

ទិញផារមេស្រុក សូកធ្វើចៅហ្វាយ ចង់ធ្វើសប្បាយ

ចាយប្រាក់រាជការ។

ធបាំងបំបាត់ លួចបានដោយស្ទាត់ អាងមានប្រាជ្ញា

ក្រលេកថ្នាំងដៃ កាលៃបោះត្រា ទាស់ក្អែកទេវតា

រក្សាផែនដី។

មួយទៀតទូរជន ធ្វើបាបបានបុណ្យ គឺបុណ្យមន្ត្រី

ទោសទៅចងចាប់ កាប់ឥតប្រណី បានបុណ្យមន្ត្រី

ព្រោះបុណ្យធ្វើបាប។

អំពើទាំងអស់ កុំសាងឲ្យសោះ ចៀសវាងដរាប

កាន់សីលព្រះពុទ្ធ ខិនលុតខិនក្រាប បើក្រដុនដាប

មានទេវតាជួយ។

កូនអើយទេវតា ស្ថិតសព្វព្រឹក្សា រងើករងួយ

មនុស្សទ្រូស្តប្បា ឯណានិមួយ ទេវតាពុំជួយ

ចំណាំស្គាល់មុន។

មិនដែលកំបាំង រាជការបារាំង គេចាប់ដាក់គុក

ដល់ខ្លួនស្លាប់ទៅ នៅរងសោយទុក្ខ សោយទោសនរក

| | | |
|---|---|---|
| | ទាំងពីរកន្ទែង។ | |
| នរកបារាំង | មានខ្សោយមានខ្លាំង | មានខ្លីមានវែង |
| នរកយមបាល | គេផ្ចាលឥតក្រែង | ព្រះអង្គសំដែង |
| | ថាលានកោដិឆ្នាំ។ | |
| ហេតុនេះគួរវាង | គួរចាលគួររាង | គួរចងគួរចាំ |
| គួរកុំធ្វើបាប | ដរាបខ្លាចកម្ម | គួរកាន់សីលប្រាំ |
| | បណ្តាំសាសនា។ | |
| ហៃកូនចៅអើយ | ក្រលាប់អស់ហើយ | មិនដូចដូនតា |
| ភ្លៀងជនខែប្រាំង | រាំងខែវស្សា | ឆ្នាំវករកា |
| | ត្រីស័កនេះឯង។ | |
| រនោចផល្គុន | រកាពីមុន | ឯកស័កដាក់ស្តែង |
| ក្នុងខ្នើតផល្គុន | ជនគ្រប់កន្ទែង | ទាំងគេទាំងឯង |
| | ធ្វើស្រែមិនបានផល។ | |
| ឆ្នាំរោងឆស័ក | វិសាខភ្លៀងធ្លាក់ | ពីររោចសំគាល់ |
| យប់ថ្ងៃអាទិត្យ | ផងផឹតព្យុះខ្យល់ | ភ្លៀងជន់ពេញថ្នល់ |
| | ពេញវាលតូចធំ។ | |
| ពេញអូរពេញជ្រោះ | ដើមឈើទាបខ្ពស់ | រលុះរលំ |
| ឬស្សីស្រុកយើង | រលើងទាំងគុម្ព | ទើបគ្រាប់វាផ្គុំ |
| | ផ្លួចដុះជាថ្មី។ | |
| ឆ្នាំចកុរជូត | រាំងរីងរហូត | គ្រប់ឆ្នាំទាំងបី |
| កើតទាំងជំងឺ | ស្លាប់មនុស្សប្រុសស្រី | ខាលឋោះអស់ក័យ |

ធ្វើស្រែស្រូវបាន។

ភ្លៀងឆ្នាំម្សាញ់ រលីងក្បាលក្រាញ់ ត្រូវតាមបុរាណ

កត្តឹកជន់វាល ពាលសព្វស្មសាន អ្នកស្ទឹងប៉ុន្មាន

រលួយស្រូវអស់។

ដាច់ថ្នល់ខានដើរ ពាជការគេប្រើ ទាំងចាស់កំលោះ

មមែរងកម្ម បញ្ចាំកេរ្តិ៍កោះ គ្មានអ្វីស៊ីសោះ

ដាច់ពោះក្សិណក្ស័យ។

ខែចែត្រឆ្នាំរក ស្រលះពពក កើតមានសម័យ

ជាហេតុអស្ចារ្យ សុរិយាល្ងាចថ្ងៃ អុត្បាតជ្រៃ

ឃើញសត្វអ្វីហោះ។

ពីជើងទៅត្បូង ចាស់ក្មេងមើលច្រូង បានឃើញទាំងអស់

មើលមិនស្គាល់ជាក់ ធ្លាក់ចំចន្ទោះ បាត់ឈឹងសូន្យសោះ

មិនដឹងទៅណា។

កាលមុននោះមក ខែបុស្សឆ្នាំរក លែងមានប្រាជ្ញា

មានតែមេស្រុក រាស់បែងក្រឡា ដីមួយហិតា

ត្រូវសែសឹបថាំង។

រង្វាន់មេស្រុក ត្រូវហូតមួយទុក ដប់ជូនបារាំង

ទៅដល់ប៉ុយរ៉ូ បង្ហូរដាក់ឃ្លាំង ពូជពីរកន្ទាំង

ក៏ជាប់ពន្ធដែរ។

គ្មានធួរគ្មានតឹង កូនអើយខំប្រឹង ជាតិឯងជាខ្មែរ

ក្មេងប្រុសជំទង់ នៅក្នុងឪម៉ែ ពាជការប្រិតប្រែ

ជាឲ្យបង់ប្រាក់។

កូនចៅប្រុសស្រី កើតមកលើដី ខំរកលុយកាក់
បានហើយប្រឹងខំ ផ្សំគ្នាទុកដាក់ គ្រាន់ទិញស្លៀកពាក់
បង់ថ្លៃរាជការ។

កទ្រូបទឆ្នាំច ចាប់គោខ្មៅស ដុតដែកបោះត្រា
ដល់កុរជូតឆ្លូវ តំរូវយ៉ាងណា នឹងកើតអស្ចារ្យ
រហូតរាល់ឆ្នាំ។

នគរថ្កើងប្លែក សប្បាយតែភ្នែក ក្នុងចិត្តវេងកម្ម
កូនប្រុសបណ្តាច់ កុំភ្លេចបណ្តាំ កប្បាសសូត្រថ្នាំ
ត្រីម៉ាំលែងថោក។

ដូងស្វាអំពៅ អំពិលស្ករស្រូវ មានទៅមានមក
មានចុះមានឡើង រាស្ត្រយើងល្មមយក ល្មមរលែលក
គួរយកគួរខាន។

កប្បាសនិងថ្នាំ គួរដាស់ដីដាំ ធ្វើដែងឯងបាន
កុំអាងខ្ជិលពេក កុំដេកឈប់ខាន កុំចោលបុរាណ
ម៉ែឪដូនតា។

ដីកេរគេរគោក កុំអាងខ្ជិលដោក ទៅឈ្មោកចិនផ្សារ
កូនចៅស្រីៗ ខំរៀនធ្វើការ បើគ្មានប្រាជ្ញា
មានមាត់ចេះស្តី។

ឲ្យសួរចាស់ៗ រៀនបោះកប្បាស ថ្លែចម្ងរសំលី
រៀនកូតរៀនការ ត្រសាររពាត់រវៃ ហូលគោមគាតក្តី

កុំបីចន្លោះ។

រៀនថ្ករៀនត្បាញ ឲ្យចាស់បង្ហាញ បង្ហាត់ទាំងអស់
សំពត់បែបផោយ លាយសូត្រអំបោះ កុំទិញគេសោះ
ឈ្មោះការជាស្រី។

ទិញដូរតែលាក់ អញ្ចូលចេសចាក់ ព្រហូតជាបី
ធ្មេញឈើឈ្នាន់ផ្សំ ក្តារមូរក្តារកី ត្រល់ខ្នារឬស្សី
មុខប្តីជាប្រុស។

តាំងពីឆ្នាំច ការអ្វីក្រៗ ខំរៀនទៅចុះ
ទាន់មានចាស់នៅ ស្គាល់ត្រូវស្គាល់ខុស ចាស់ស្លាប់រលស់
គ្មានមនុស្សចេះដឹង។

រកស៊ីឲ្យញឹក ដេកយប់រលឹក រឹតក្បិនឲ្យតឹង
បើភ្ញាក់កាលណា កាន់ការកាលនឹង កូនអើយខំប្រឹង
ទាំងប្រុសទាំងស្រី។

រមៀតស្ពឹកគ្រៃ ដីរម្ទេសខ្ទឹមខ្ទី មានដីដាំចុះ
ដាំដើមអ្វីៗ ចំណីគ្រប់ឈ្មោះ គ្រឿងស៊ីផ្លែតពោះ
ផុះចោលទទេ។

ផុះទិសខាងជើង ផុះដាក់ដីយើង កុំផុះដីគេ
កុំផុះដាក់ផ្លូវ ត្រូវមាត់ក្មេងជេរ ដីសល់ទំនេរ
ល្មមមាត់ផុះទៅ។

សក់មួយជាដប់ ជ្រៀតសិតឲ្យសព្វ កុំឲ្យសល់នៅ
បើប្រាជ្ញារាក់ ចាក់ចិត្តឲ្យជ្រៅ ដាំចេកអំពៅ

ដូរស្រូវអង្ករ។

កើតមកជាមនុស្ស មួយព្រួយចង់រស់ មួយព្រួយចង់ល្អ
ពីនេះជាធំ វានាំឲ្យក្រ ចាំជាតំណ
តជាទំនុក។

មនុស្សមារយាទមិនប៉ិន កូននៅខ្ញុំចិន ព្រោះម្តាយឪពុក
ធ្វើស្រែមិនត្រូវ គ្មានស្រូវជង្រុក កូនអើយចាំទុក
នេះមុខមេក្រ។

មេ១ជាធំ កំលោះក្រមុំ ស្មៀកពាក់ចង់ល្អ
បើបានបែបខ្មៅ ថានៅបែបស ទើបគ្រាន់អន់ក្រ
ត្រូវរចង់ថ្កើង។

ក្រលាប់នគរ រីងរឹតកើតចោរ ច្រើនឡើងច្រើនឡើង
ពាលរឹងក្រអើត ថើតម៉ើតថើតម៉ើង ក្រដាស់យ៉ាងស្តើង
ចាយរហែកនៅដៃ។

ប្រាក់ចាយអស់ទៅ ព្រោះមនុស្សឥឡូវ អុត្សាតចង្រៃ
ជាតិខ្មែរប្រែភេទ ក្រលែតក្រលៃ ក្រលាស់សាសន៍សៃយ
សព្វសត្វនានា។

ជាតិខ្មែរប្រែខុស ស្រីក្លែងធ្វើប្រុស ប្រុសក្លែងធ្វើផ្កា
យកប្តីប្រពន្ធ មិនស្គាល់មីងមា បុណ្យទានការងារ
កាប់គ្នាឥតក្រែង។

ល្ងង់រិកធ្វើចេះ គោចងត្រដោកសេះ ប្រុសៗដុះស្នែង
ស្រីពាក់អាវខ្លី ប្រុសពាក់អាវវែង សារុងហៀរកែង

ផ្អើងផងអ្នកគ្រាន់។

កាន់ចិត្តសីហលោ សេះទឹមនឹងគោ ចាក់ហ៊ោលាន់ៗ
រកស៊ីមួយថ្ងៃ ចង់បានមួយពាន់ បរគោជល់មាន់
ចាក់កាប់ជាប់គុក។

រីល្បែងបៀប៉ោ ច្រើនទៅជាចោរ ប្រកាសហាមទុក
ចូរកូនប្រយ័ត្ន ប្រយោជន៍ទៅមុខ ចាំជាទំនុក
ដំណកូនចៅ។

អ្នកកុំប្រហែស រាជការនិរទេស កំចាត់ចេញទៅ
រាជការអាណិត ខំប្រិតប្រដៅ កុំលោភល្ងង់ខ្លៅ
ថោកផៅត្រកូល។

ប្រយ័ត្នក្រែងក្រ ផ្លូវច្បាប់ល្អៗ អ្នកខំប្រមូល
ផ្លូវវៀចអាក្រក់ អ្នកកុំដើរចូល ហៅផ្លូវមិនស្រួល
លង់ផុតគំនិត។

ដើរផ្លូវកណ្ដាល ស្រលាញ់ស្និតស្នាល ឈើឆ្កាលដោយពិត
មគ្គផលសីលទាន ឈានចូលឲ្យជិត យកធម៌ជាមិត្រ
មិនឥតអំពើ។

មនុស្សម្នាក់ច្រើនឆោត ច្រើនគ្មានគេកោត ឈើគ្មានគេមើល
ស្លាប់ឥតគេព្រួយ គេជួយទាំងស្ទើរ មិនដែលឡើងលើ
ប្រមុះចុះក្រោម។

កូនចៅស្រីៗ ក្រមុំសាវខ្ចី រៀនឆោតឲ្យល្មម
ប្រុសស្មើម៉ែឪ ធ្វូរធប្រលោម មើលរូបមើលឆោម

កុំព្រមដោយងាយ។

កុំក្និចក្នក់ក្នាញ់ បើចិត្តស្រលាញ់ កុំចេញនិយាយ
បើស្អប់កុំប្តឹង បើខឹងកុំធ្វាយ កុំពោះកុំពាយ
កុំងាយធ្វើស្និទ្ធ។

កុំដើរប្រាប់គេ កុំអាងអួតជេរ ក្រែងប្រុសឈឺចិត្ត
នៅឲ្យតែនឹង កុំរវល់ធ្វើស្និទ្ធ ប្រុសនឹងអាណិត
គិតចូលដណ្តឹង។

បើម៉ែឪឲ្យ មើលមុខមើលក្រោយ អាក្រក់ខ្មៅធ្មឹង
ប្រកែកដោយស្វាត់ កុំខ្វាចម្តាយខឹង កើតកូនមកតឹង
ពិបាកចាយណាស់។

កុំឃ្វានចំណី កុំខ្វាចអត់ប្តី កុំភ័យខ្វាចចាស់
មើលមុខឯងផង កុំរើសឥតខ្នាស ខ្លួនល្អស្រលះ
មិនខ្វះគេស្តី។

បើបានជាខូច ទាន់ផើមនៅតូច ខែពីរខែបី
រៀសធ្វើយប្រញាប់ ប្រាប់គ្នាស្រើៗ កុំលាក់ធ្វើអី
ក្នុងតែគេដឹង។

កុំមាយាបេះក្រូច មារយាទចេះតែខូច មាត់ចេះតែខឹង
គេថាត្រង់ណា ជេរគេត្រង់ហ្នឹង ជេរហើយខំប្រឹង
យកថ្មសង្កត់។

រំលាយរំលូត អាក្រក់តែគូទ អួតល្អតែមាត់
មានគេឃើញច្បាស់ ម្ទះរឹងហ៊ានស្បថ ទោសនេះនឹងភ្ជាត់

ធ្លាក់ទៅអវចី។

ចោរកាចលួងខ្មៅ ប្រាជ្ញប្រាមប្រដៅ ហៅបារាជិកស្រី
មេបាគេកាច់ ស្លាប់ពីរស្លាប់បី រំលូតកូនខ្ចី
ស្មើរំលាយព្រះ។

មានកាលមានក្ស័យ ខ្វិនជើងខ្វិនដៃ កខ្វេះកខ្វាស
ខ្វាក់ភ្នែកអន្ធការ អនិច្ចារូបណាស់ អាក្រក់កេរ្តិ៍ខ្មាស
តកូនតចៅ។

អសោចសុសសាយ សុសសព្វដល់ម្ដាយ ដល់ពូជពង្សដៅ
ស្លាប់ទៅវេទុក្ខ នរកឋានក្រៅ គេស្រុះទឹកក្ដៅ
ស្លាប់ទៅរស់ទៀត។

ស៊ីខ្ទះឈាមឯង ព្រះអង្គសំដែង ថាមុឺនសែនជាតិ
ឡើងមកជាប្រេត ហេតុកម្មមិនឃ្លាត អត់ឃ្លាតគ្មានញាតិ
ហែកកូនឯងស៊ី។

ព្រះពុទ្ធលែងប្រោស ធម៌លែងសន្ដោស សោយទុក្ខវក់វី
ហេតុចិត្តឫស្យា មិច្ឆាទិដ្ឋី កើតជាជ្រូកញី
គេគ្រៀវគេចាក់។

អសង្ហើយឆ្នាំ ហេតុផលសេសកម្ម កើតជាមនុស្សខ្វាក់
មនុស្សខ្វិនទ្រេមទ្រម ជាគមជាគាក់ ខ្ទើយឆ្កួតអបលក្ខណ៍
ជាអ្នកឥតប្ដី។

បើម្ដាយជួយព្រួត ជួយនាំរំលូត រំលាយកូនខ្ចី
នរកប្រេតព្រមគ្នា មិនឃើញរស្មី ត្បិតចិត្តតិរ្ថិយ

ទាំងម្តាយទាំងកូន។

ហេតុនេះគួរខ្លាច ធម្មតាចោរកាច មិនដែលស្ងាត់ស្ងៀម
អសោចកេរ្តិ៍ឈ្មោះ ទាំងអស់បងប្អូន មេបាតាដូន
កាត់កាលលែងរាប់។

គួរប្រុងអិរិយា កើតទាន់សាសនា ហៅមហាមានភ័ព្វ
ទាំងស្រីទាំងប្រុស កុំបីឲ្យធ្លាប់ គួរខំរៀនផ្គាប់
បរលោកលោកិយ។

ឯខុសនឹងគាប់ បើនឹងរៀបរាប់ រាល់រូបប្រុសស្រី
គាប់ខុសនៅចិត្ត ខុសគាប់នៅស្តី គំរប់ជាបី
ខុសត្រូវនៅកាយ។

កូនប្រុងប្រព្រឹត្ត ការកេរ្តិ៍ឲ្យជិត គំនិតឲ្យឆ្ងាយ
កើតមកជាខ្មែរ កុំប្រែក្លែងក្លាយ ធម្មតាសប្បាយ
វាតែងឲ្យទុក្ខ។

ឲ្យទោសឲ្យទែង ទាស់តែម្នាក់ឯង ដល់ម្តាយឪពុក
រីឯរឿងទោស មានតែពីរមុខ មួយនៅនរក
មួយនាលោកិយ។

លោភៈទោសោ កើតពីមោហោ រាល់រូបប្រុសស្រី
គួរកាន់មេត្តា កតញ្ញូខន្តី នេះជាបាលី
ទៅកាន់បរលោក។

ពាក្យពិតប្រដៅ ឲ្យអស់កូនចៅ ប្រព្រឹត្តរៀនយក
កូនណាមិនរៀន កូននឹងមារយាទថោក នឹងធ្លាក់ជ្រុលជ្រក

ក្នុងចតុបាយ។

ជំស្រេចនៅស្ងួត សុខខ្លួនរហូត ដរាបវែងឆ្ងាយ
ខន្តីអំណត់ សង្កត់ក្នុងកាយ ជាតិជនទាំងឡាយ
កំរកាន់បាន។

ចេះហើយមិនដឹង ចិត្តនៅម្នះរឹង ប្រឹងរកកម្មដ្ឋាន
រកធម៌មិនយល់ ខ្ជិលខ្វល់ឈប់ខាន បន្ទោសបុរាណ
ថាគ្មាននិស្ស័យ។

វីបាបនិងបុណ្យ មានចិត្តជាមុន មាត់ជាបច្ច័យ
នាំចុះនាំឡើង ពីជើងពីដៃ សន្សំសព្វថ្ងៃ
ឈ្មោះហៅសំណាង។

កើតក្នុងលោកិយ រាល់រូបប្រុសស្រី មានចិត្តមានអាង
កុសលអកុសល ប្រទាញសងខាង រូបនៅតែងតាង
តែងតាមទៅមក។

មគ្គផលសីលទាន បើល្ងង់ឲ្យរៀន បើគ្មានឲ្យរក
យល់ល្អសាងស្អាត សង្វាតជ្រៀតជ្រក ជ្រើសរើសរៀនរក
រក្សារូបកាយ។

នេះជាហៅច្បាប់ ជាទីសណ្តាប់ សណ្តានទាំងឡាយ
កូនចៅប្រុសស្រី កុំបីនឿយណាយ សង្ខេបបរិយាយ
និដ្ឋិតំបែងចប់។

អ្នកព្រះភិរម្យ អាចារ្យង៉ុយខ្ញុំ បង្គំប្រាមដប់
លើសលស់ផ្តាំផ្តង រំលងពុំគាប់ ពុំគួរសមសព្វ

សុសសាយសេចក្ដី។

| | | |
|---|---|---|
| កាយកម្មវចីកម្ម | ឈ្មោះច្បាប់បណ្ដាំ | កូនចៅប្រុសស្រី |
| ជាបរមត្ថក្រៅ | មិនហៅបាលី | បរលោកលោកិយ |
| | ទាំងពីរកន្ទេង។ | |
| បើលោកឯណា | ចេះចាំធម៌អាថិ | ប្រាកដជាក់ស្ដែង |
| ឃើញខុសត្រង់ណា | កុំថាជាល្បែង | ដ្បិតពាក្យខ្ញុំតែង |
| | ឲ្យក្មេងវាភ័យ។ | |
| មិនមែនភរភូត | កុំថាខ្ញុំអួត | ប្រាជ្ញាខ្ញុំវៃ |
| ឃើញមនុស្សវង្វេង | ខ្ញុំតែងច្បាប់ថ្មី | អស់អាថិសេចក្ដី |
| | អេរំចប់ហោង។ | |

# ពាក្យកាព្យប្រដៅជនប្រុស-ស្រី

ខ្ញុំសូមបង្គំព្រះសម្មា
សម្ពុទ្ធណាៗក្នុងត្រៃភព
ចំរើនកម្មដ្ឋានក្រោមពោធិ៍ម្លប់
ខ្ញុំសូមគោរពនមស្សការ។
ព្រះចមចក្រពិននរិន្ទឫទ្ធិ
ជាម្ចាស់ជីវិតលើសិរសា
សូមថ្វាយបង្គំព្រះករុណា
សូមទ្រង់មេត្តាប្រោសប្រណី។
ឱនកាយបង្គំប្រណម្យនឹក
សូមក្រើនរំលឹកវាស្ត្រប្រុសស្រី
ធ្លាប់ជ្រកពឹងពាក់ព្រះបារមី
ឲ្យរៀនបាលីទៅបរលោក។
សរណគមន៍បីឲ្យប្រតិបត្តិ
កំចាយកំចាត់ក្ដីទុក្ខសោក
រូបយើងសព្វថ្ងៃថ្ងៃមិនថោក
បានមកភពភាន់ទាន់សាសនា។
ផ្លូវប្រេតនរកទៅញឹកញយ
គួរកុំបណ្ដោយតាមតណ្ហា
គួរគិតសង្វេបឃាត់សង្ខារ
សង្ឃឹមព្រះសិអារ្យនឹងមកត្រាស់។
ជម្ពូទ្វីបនេះធំបំផុត
មួយម៉ឺនយោជន៍គត់ដំណែលព្រះ
សត្វស្លាប់តាមកម្មមិនចាំចាស់
អាយុខ្ទីណាស់ក្រាស់អកុសល។
រូបំ អនិច្ចំ អនត្តា
កើតរូបកាលណាកម្មតាមដល់
តាមដានដរាបបានឲ្យផល
បាបខ្លះសេសសល់ពីនរក។
ខ្លះមកពីប្រេតតិរិច្ឆាន
ខ្លះមកពីស្ថានសួគ៌សោយសុខ
វេរាតាមរកបានឃើញមុខ
ចុះមករងទុក្ខទទួលកម្ម។
អ្នកធ្លាក់ទៅរងនរកប្រេត
ដើមហេតុពីព្រោះដាច់សីល៥
ទឹកក្ដៅខ្លះដែកទៅដេកត្រាំ
រាប់លានកោដិឆ្នាំទំរាំរួច។
មកកើតជាមនុស្សស្ថានកណ្ដាល
មិនរាងមិនចាលដល់តិចតួច

ប្រពន្ធកូនគេនៅតែលួច សត្វធំសត្វតូចរឹតសំលាប់។
ស្រារឹតតែផឹកឲ្យស្រវឹង គុណទោសមិនដឹងប្រឹងចាក់កាប់
ស្រុកឃ្លានបំពានធ្វើលើច្បាប់ មិនស្តាប់ពុទ្ធដីកាព្រះអង្គផ្តាំ។
ពិតមែនជាមិនលឺព្រះឱស្ឋ ព្រះសង្ឃទ្រង់ប្រោសឲ្យសីល៥
ទទួលរំពេចភ្លេចមិនចាំ ប្រព្រឹត្តសាងកម្មមិនព្រមលែង។
កើតមកពូជពង្សពេញជាមនុស្ស សេចក្តីត្រូវខុសចាំជាក់ស្តែង
សំលាប់រូបសត្វឥតគិតក្រែង បំពេញរូបឯងឲ្យធំជាត់។
សំលាប់មិនថាសត្វឈ្មោលញី យកសាច់មកស៊ីឲ្យឆ្ងាញ់មាត់
ទទួលសីលភ្លើធ្វើឲ្យភ្ញាត់ លក់សត្វឲ្យព្រាត់មេព្រាត់កូន។
ព្រាត់គូកំសត់វដ្តសង្សារ ដូចលក់ជីតាលក់ជីដូន
ពុំនោះលក់បងបំបែកប្អូន ផងផឹតឈឹងសូន្យមើលមិនយល់។
ខ្វះទៅនរកមិនទាន់មក ខ្វះឃ្លាតទៅជ្រកពួកអសុរ
ជវនៃសង្ខារឡប់វិលវល់ អំពល់តែកើតស្លាប់កើតស្លាប់។
កម្មកិតតាមខ្លួនមិនដែលឃ្លាត គ្រប់ប្រាំរយជាតិមិនដែលធាប់
សត្វជ្រូកមាន់ទាគេចាក់កាប់ សំរាប់គេស៊ីជាអាហារ។
សត្វគោក្របីដំរីសេះ គេជិះគេទឹមជាធម្មតា
គេកាប់លក់សាច់ផ្តាច់សង្ខារ រកចិត្តមេត្តាករុណាគ្មាន។
រូបខន្ធរលត់រលាយទៅ សល់នៅសង្ខារនិងវិញ្ញាណ
វេទនាសញ្ញានឹកស្រុកឃ្លាន សន្និដ្ឋានថាដូចអ្នកមានគុណ។
សត្វញីសត្វឈ្មោលអន្ទោលទុក្ខ អាពុករឺម្តាយពីជាតិមុន
ជាតិមកពីរងទោសទុក្ខធ្ងន់ ក្រែងស៊ុនទៅលើសាច់ញាតិឯង។

| | |
|---|---|
| ជ្រូកគោក្របីនៅតូចស្នាវ | គេក្រៀកវះក្រៀវឃើញស្តែងៗ |
| បើគិតឲ្យសព្វគ្រប់កន្ទែង | ជូនក្រែងជាតិមនុស្សមកជាសត្វ។ |
| អ្នកពឹងនិងអ្នកធ្វើដៃដល់ | ចៅក្រមអកុសលជំនុំកាត់ |
| បញ្ជីរទាំងពីរឈ្មោះមិនបាត់ | គេចាត់ធ្វើទោសទាំងអស់គ្នា។ |
| មិនមានអ្នកណាធ្ងន់ណាស្រាល | យម្កបាលវះក្រៀវគ្រប់វេលា |
| មានលោកយមរាជរាជសភា | ជំនុំគិតគ្នាមើលបញ្ជីរ។ |
| បញ្ជូនអ្នកធ្វើចុះនរក | ជំនុំឃុំទុកអ្នកទិញស៊ី |
| ទិញសត្វស្លាប់រស់ទោះឈ្មោលញី | ទាំងពីរចំណែកចំណាំមុខ។ |
| អ្នកមួយទិញស៊ីមិនរួចខ្លួន | ត្រឹមឯត្រីអួនយួនដូរលក់ |
| អណ្តែងក្រាញ់ឆ្តោដៀបរ៉ស់ផ្ទក់ | ចង់ទិញស្ងោរជ្រក់ទៅតថ្ងៃ។ |
| ឃើញច្បាស់ជារស់មិនទាន់ងាប់ | អង្គុយបង្អាប់ឲ្យយួនវ៉ៃ |
| រកខ្យល់ប្រលោតដោតញ័រដៃ | ឃើញក្ប៉យស្រាប់ៗមិនទិញយក។ |
| អានេះបន្ទរលែងមិនបាន | ត្រូវប្រំជាក់ប្រានឲ្យជ្រុលជ្រក |
| ទំលាក់ឲ្យជ្រៅរងទុក្ខសោក | លែលកអ្នកទោសរឿងអ្នកទិញ។ |
| អ្នកទៅឃើញត្រីនៅបំរះ | វេទនាចិត្តណាស់ប្រាសដើរចេញ |
| អ្នកនេះត្រូវលែងឲ្យទៅវិញ | មានសែហ្វលិញគិញក្នុងនរក។ |
| ឲ្យជូនខ្លាចក្រែងវង្វេងផ្លូវ | ត្រួតមើលខុសត្រូវគ្រប់ភូមិស្រុក |
| បើកក្រាំងសៀវភៅកត់ឈ្មោះទុក | បញ្ជីពីរមុខបាបនិងបុណ្យ។ |
| ប្រគល់យមរាជយម្កបាល | ដាក់ស្រាលដោយស្រាលធ្ងន់ដោយធ្ងន់ |
| អ្នកសាងមគ្គផលស្គាល់ទោសគុណ | ទៅសោយសុខមុនតាមទុនទាន។ |
| អ្នកសាងធុនទាបភាពអកុសល | មិនចង់បានផលសួគ៌និព្វាន |

ប្រព្រឹត្តអាក្រក់រកល្អគ្មាន    មិនហ៊ានកាន់សីលថាខ្លាចដាច់។
មិច្ឆាទិដ្ឋិចូលពេញទី    បញ្ជីសំរាំងតាំងសំរេច
ចុះវង្សអាជីវកក្ខក់ស៊ីអាចម៍    ព្រោះពោលបង្អាច់ព្រះពុទ្ធដីកា។
វចីទុច្ចរិតមានគ្រប់យ៉ាង    ទានសីលមិនសាងអាងផឹកស្រា
លីលោកសំដែងធម៌ទេសនា    ពិរោះពិស្តារមិនចេះស្តាប់។
អស់យើងគួរស្តាយជាតិកំណើត    សំណាងមកកើតក្នុងភទ្ទកប្ប
អគារវិន័យព្រះប្រញប្ត    ជាឫគល់ច្បាប់គួររក្សា។
សីល៥ ចង់ចាំឲ្យប្រាកដ    កុសលកម្មបថ១០ប្រការ
កុំឈ្លោះប្រកែកពីធម៌អាថ៌    ប្រកាន់សាសនាឲ្យប្រាកដ។
កើតមកជាមនុស្សមានសខ្មៅ    មានប្រាជ្ញមានខ្លៅមានក្រខ្សត់
មានខ្លាំងមានខ្សោយដោយបែបបទ    សន្មតថាល្អក៏មិនបាន។
ជម្ពូទ្វីបនេះមនុស្សកម្មក្រាស់    ព្រះពុទ្ធតែងត្រាស់មិនដែលខាន
ហេតុនេះមហាជនទាំងប៉ុន្មាន    សំរាកសំរាន្តសំរួលចិត្ត។
បំណាច់សម្តេចព្រះទ្រង់ញាណ    កាលហៀបនិព្វានមានកំរិត
ផ្តាំមហាអានន្ទឲ្យអាណិត    អនុជអ្នកប្រឹតប្រោសសត្វផង។
សត្វផុងទៅក្នុងជ្រោះជ្រាំជ្រៅ    តថាគតនៅនាំចំលង
ដាក់ដល់និព្វានអស់ហ្មត់ហ្មង    រួចពីចំណងវដ្តសង្សារ។
នៅសល់សង្ស័យសត្វខាងក្រោយ    នន្ទអើយទុកឲ្យព្រះសិអារ្យ
អាណិតសត្វណាស់ណាអ្នកណា    តថាគតជិតនិព្វានហើយ។
ព្រះឱស្ឋព្រះអង្គល្ហមស្រណោះ    សប្បុរសទាំងអស់កុំកន្តើយ
ប្រះខ្នងដេកលើកន្ទេលខ្នើយ    កុំស្មៀមមាត់ឡើយរំលឹកគុណ។

ខ្លួនខ្ញុំកំណើតពាស្ត្រអ្នកស្រែ ខូចខិលខ្ជិលដែរពីកាលមុន
កាលមោហ៍បាំងបិទងងឹតស៊ុន ធ្វើបាបនិងបុណ្យទំងន់ស្មើ។
មិនស្មោះតែរួចចតុរាបាយ អស់លោកទាំងឡាយកុំសរសើរ
ខ្ញុំជួនដំណឹងតាមដំណើរ ព្រោះខ្ញុំគ្រាន់បើជាងអ្នកល្ងង់។
ជាតិក្រោយកុំឲ្យខ្ញុំល្ងីល្ងើ ជាតិនេះចាស់ស្មើរខ្ញុំប្រឹងស្ទង់
ប្រឹងស្ទុះឲ្យរួចពីអន្ទង់ ភ័យភិតខ្លាចផុងទៅក្នុងភក់។
ក្នុងភពសង្សារខ្ញុំសង្ស័យ សព្វថ្ងៃខ្ញុំភ័យខ្លាចនរក
ម្យ៉ាងទៀតខ្ពើមជាតិអាជីវក ជាតិល្មោភហួបល្មក់ព្រោះល្មិលគុណ។
ច្រើនល្មើសបន្ទួលបន្ទោសព្រះ ខ្ញុំភ័យខ្ញុំណាស់ក្រែងខ្ញុំស៊ុន
ខ្ញុំសូមស្មាលាទោសពីមុន សូមបុណ្យជួយបាំងបាបឲ្យបាត់
ឲ្យបានទាន់តួព្រះសិអារ្យ ឲ្យបែកប្រាជ្ញាឆ្លាតបរមត្ថ
ព្រះអង្គទេសនាទ្រង់ប្រោសសត្វ សូមលុះអរហត្តដូចបំណង។
បំណាច់ខ្ញុំផ្សាយច្បាប់រំលឹក អស់លោកជួយនឹកសច្ចាផ្សង។
ធ្វើបុណ្យចែកផលដល់ខ្ញុំផង នឹកឈ្មោះម្ដងៗដូចធម្មតា។
សប្បុរសប្រុសស្រីគប្បីស្ដាប់ ឈ្មោះច្បាប់កន្ទងព្រះឱង្ការ
ឱកាសឲ្យគិតប្រឹតប្រាជ្ញា ទាន់ព្រះសិអារ្យទាំងប្រុសស្រី។
កុំរៀនព្រហើនប្រហែសធ្វេស កើតក្នុងប្រទេសរាជបុរី
ឲ្យមានបារម្ភភ្ញាក់ស្មារតី សីលប្រាំប្រាំបីខំសិក្សា។
ជាតិមនុស្សជាន់ខ្ពស់ពីបុរាណ គេបានជួបជាក់ឃើញភគ្គ្រា
បានត្រងរងត្រាប់ព្រះពុទ្ធដីកា បានលុះសោតាអរហត្តហោះ។
យើងទាន់តែត្រឹមពាក្យបណ្ដាំ បណ្ដូលសីលថជាកេរ្តិ៍កោះ

កិច្ចការកង់កម្មចាំមិនអស់ របស់ឫគល់គួររក្សា។
នេះចប់ចំណែកខាងបាសក កុំធ្វើអាក្រក់រាល់រូបបា
រំពឹងក្រែងជួបព្រះសិអារ្យ នមស្សការគោរពរំលឹកគុណា។
ព្រះចមចក្រពង្សមុនីនាថ កំពូលផុតជាតិជាងមហាជន
ទ្រង់សោយសម្បត្តិសំបើមបុណ្យ សំបូណ៌លើសលន់លុបលោកា។
លោកកីយដឹងហើយគួរកោតខ្លាច ទ្រង់មានអំណាចព្រះចេស្តា
គួរស្តាប់ព្រះរាជឱង្ការ បន្ទូលត្រួតត្រាគួរត្រងត្រាប់។
ព្រះទ័យទ្រង់ត្រេកស្រលាញ់សង្ឃ ប្រមាណសែនអង្គក្នុងភទ្ទកប្ប
ព្រះពុទ្ធទ្រង់ប្រិតប្រាមប្រញប្ត ឈ្មោះច្បាប់បាដិមោក្ខសំវរសីល។
ចែកចេញជាកងសិក្ខាបទ កំណត់ពីរយម្ភៃប្រាំពីរ
មិនឲ្យមានមោះហ្មងមន្ទិល អ្នកបួសកុំខ្ជិលកាន់ឲ្យខ្ជាប់។
បាណាអទិន្នាជាបឋម ជាតិរូបទៀតផ្សំត្រូវជាដប់
លោកសង្ឃឥឡូវកាន់មិនសព្វ កាន់ក្នុងបន្ទប់លាយបន្ទំ។
បន្ទិចលុយកាក់សំងាត់ ទោសត្រូវអាបត្តិលាក់សំងំ
បាសកផ្ញើទានគ្មានអារម្មណ៍ សន្សំតែទ្រព្យក្តៅក្រហាយ។
ប្រសិនបើកាន់ច្បាប់ព្រះពុទ្ធ មិនមានជម្មយុត្តិមហានិកាយ
បើចេះខ្លាចក្រែងមិនក្វែងក្វាយ សមសុខសប្បាយមិនទាស់គ្នា។
លោកសង្ឃគ្រប់វត្តមានជំតូច សង្ឃខ្លះខិលខូចសង្ឃខ្លះជា
បរិស័ទថ្កោលទោសគ្រូឧបជ្ឈាយ៍ មានពាក្យនិន្ទាតែរាល់វត្ត។
បាដិមោក្ខពីររយម្ភៃប្រាំពីរ អ្នកល្ងង់ហើយខ្ជិលចាំមិនស្ទាត់
កងបាចិត្តិយនិងទុក្កដ ចូលមាត់ចូលកមិនដឹងខ្លួន។

កងបាចិត្តិយកៅសិបពីរ និស្សគ្គិយ៍សាមសិបបារាជិកបួន
បើចេះហើយចាំឲ្យមាំមួន ល្អបរិសុទ្ធសួនមិនសាយសុស។
ប៉ុន្តែសិក្ខាមិនសូវចាំ ចំណាំត្រង់ណេះចោលត្រង់ណោះ
ត្រង់ណាដែលដឹងជាខ្លួនខុស ហ៊ានឈ្លោះពីព្រោះគេមិនដឹង។
សង្ឃាទិសេសប្រហែសបាន ដប់បីសន្តានប្រមាណថ្មីង
បើផ្ទាប់សង្រួមឲ្យយ៉ាងតឹង មិនអរមិនខឹងមិនខាតខុស។
ឥន្ទ្រិយ៍ប្រាំមួយនាំឲ្យភ្ញាត់ បាចិត្តិយទុក្កដលាយចំរុះ
ឥន្ទ្រិយ៍ត្រចៀកភ្នែកច្រមុះ ភ្នែកមើលណេះណោះឃើញសុសសាយ។
សោតិន្ទ្រីយោស្ទូរតិចខ្លាំង ចក្ខុន្ទ្រីយ៍ឃើញជិតឆ្ងាយ
ជីវ្ហិន្ទ្រីយាពោលនាយអាយ សើចលេងសប្បាយចំអន់គ្នា។
បរិស័ទអាបត្តិទុក្កដញឹក បារាជិកច្រើនណាស់តែឧបជ្ឈាយ៍
ទ្រព្យក្នុងសំបាច់សំបូណ៌ហៀរ ត្រូវទោសអទិន្នាគរុភណ្ឌ។
ទ្រព្យសង្ឃជាដើមគឺចំណាំ អវហារម្តេប្រាំចាំគ្នេរគ្នាន់
ឱបទុកខ្វះខ្នែងគ្រែងមិនគ្រាន់ អវហាប្រាំជាន់បារាជិក។
ម្យ៉ាងទៀតទ្រព្យសង្ឃក្នុងចំណែក កិបទុកមិនចែកឲ្យលោកភិក្ខុ
គ្រឿងយារជីវិតកាលិក ទុកខួបល្ងាចព្រឹកម៉ៅតែឯង។
ម្យ៉ាងទ្រព្យគេហែចូលវិហារ បាសកបូជាដល់គម្តែង
គេវេរបាលីមានខ្វីវែង គេតែងនឹងថាសង្ឃស្សរ។
ប្រកាសប្រគេនជំនុំសង្ឃ ចំពោះគ្រប់អង្គជាទេមៈ
លោកសង្ឃសាធុគ្មានសល់ម្នាក់ សង្ឃរាជទុកដាក់មិនចែកចាយ។
ខ្ញុំបាទតែងតាមខ្ញុំចេះចាំ អវហារម្តេប្រាំបែបបរិយាយ

នេះសុទ្ធតែសីលផ្លូវអន្តរាយ លោកសង្ឃទាំងឡាយកុំប្រព្រឹត្ត។
ពីព្រោះអិន្ទ្រីយ៍ទាំង៦ លោកណាមិនព្រួយមិនប្រុងគិត
លោភៈមោហៈបាំងងឹត សិស្សមានគំនិតមិនហ៊ានថា។
សូមទានសន្តោសសំដែងច្បាប់ ព្រះសង្ឃកុំចាប់ចងទោសា
ខ្លួនខ្ញុំសូមសុំបវារណា ប្រោសប្រាណមេត្តាគ្រប់បណ្ដាសង្ឃ។
ខ្ញុំមិនមានពោលពាក្យបង្អាច់ ខ្លាចសីលលោកដាច់ខ្ញុំតំរង់
តំរូវតែតាមច្បាប់ព្រះអង្គ ព្រះឱស្ឋត្រឹមត្រង់ត្រូវមាត្រា។
កាលអង្គសំដេចព្រះចមភព បន្ទូលប្រារព្ធគ្រប់ប្រការ
ប្រកាសប្រាកដបទសិក្ខា ប្រញាប្តប្ដេជ្ញាមហាបរិស័ទ។
ភិក្ខុភិក្ខុនីអស់អរហន្ត អានន្ទមិនទាន់បានអរហត្ត
ព្រះធម៌វិន័យកុំឲ្យបាត់ ប្រយ័ត្នឲ្យគង់ប្រយោជន៍យូរ។
ក្រោយនោះព្រះអង្គចូលនិព្វាន អរហន្តហោះធ្យានមានជាគ្រួ
មិនមានអ្នកណាដាក់ទូ ទេសនាបង្អូរពីព្រះឱស្ឋ។
ព្រះអគ្គសាវ័កគ្រប់ព្រះអង្គ ព្រះទ័យស្រោចស្រង់ទ្រង់សន្ដោស
សំដែងធម៌អាចិមេត្តាប្រោស បាបបុណ្យគុណទោសនិងសីលទាន។
ឈ្វេងយល់ថាធម៌នឹងសូន្យស្ងាត់ អហន្តអរហត្តចូលនិព្វាន
សង្ឃសេក្ខបុគ្គលមិនទ្រង់ញាណ មិនមានអ្នកណាតែងទុក។
ព្រះធម៌ប្រាំបីម៉ឺនបួនពាន់ ស្រេចលើអានន្ទចាំទំនុក
ដំនែលព្រះអង្គដឹងគ្រប់មុខ ជម្រុកធម៌អាចិមហាអានន្ទ។
ជាព្រះអនុជអាណិតសត្វ ក្រែងបាត់បិដកមិនគ្រប់គ្រាន់
ព្រះធម៌ប្រាំបីម៉ឺនបួនពាន់ ត្នេរត្នាន់ខ្នះខ្នែងចាត់ចែងចារ។

| | |
|---|---|
| ចេះចប់អភិធម្មចាំរហូត | វិន័យព្រះសូត្រ៥ប្រការ |
| ប្រកាសអស់អង្គអរហន្តា | បិដកឯណាជាឫគល់។ |
| បមត្តព្រះសូត្រអានន្ទចាំ | វិន័យទាំង៥ ឧាលីយល់ |
| អរហន្តទាំងអស់កើតរវល់ | អំពល់អីពីរឿងធម៌អាជិ។ |
| ព្រះបាទអជាត:សត្រូវ | ជួយគិតតំរូវព្រះសាសនា |
| សម្មតិឲ្យឈ្មោះហៅក្សត្រា | ព្រោះព្រះមហាក្សត្រីយចូលគំនិត។ |
| និយាយឲ្យដឹងដើមកំណើត | កកើតអក្ខរាចារស៊ឹករិត |
| បកប្រែបាលីសេចក្តីពិត | ពិនិត្យត្រឹមត្រូវតាមពុទ្ធដិកា។ |
| ទសជាតក៍ទាំង១០មានគ្រប់វត្ត | ប្រែត្រូវប្រាកដព្រះគាថា |
| ព្រះធម៌សូត្រមន្តរីសូត្រដារ | អ្នករៀនអក្ខរាពីរចំណែក។ |
| ចំណោះចំណាំចាំដោយខ្លួន | ខ្វះរៀនមានក្បួនចាស់ចារចែក |
| ហ៊ានភ្នាល់ព្រោះអាងឃើញនិងភ្នែក | កើតឈ្មោះប្រកែកប្រកួតខឹង។ |
| ប្រកាន់តែខាងខុសរហូត | មិនរៀនមេសូត្រឲ្យចេះដឹង |
| អាងចេះតែ ក កាប៉ុណ្ណឹង | ខំប្រឹងចំអើតអួតខ្លួនត្រូវ។ |
| ក្តៅណាស់ពីរឿងយោជាយ៉ោ | តំលើងភ្នែកស្មោមុខក្រញូវ |
| ថាធ្លាប់យោនាពីខ្មោចឪ | ឥឡូវយ៉ោណាមិនសុខចិត្ត។ |
| អ្នកម្ខាងអាងស្រះតួប្រាំបី | ឲ្យដឹងបាលីជាកំរិត |
| ផ្សំតួមេសូត្រប្រឹងប្រែប្រឹត | ព្រោះត្បិតឲ្យត្រឹមត្រូវមាត្រា។ |
| អ្នកបួសគ្រប់វត្តគ្រប់នគរ | ស ដាក់ជើង លរាប់ស្វស្វា |
| បើ ស ជើង ម រាប់ស្មស្មា | នាក់មានប្រាជ្ញាល្មមស្តាប់បាន។ |
| កុំល្ងង់ទាល់ផាប់ធ្លាប់មិនដឹង | បើខឹងខ្ញុំឃាត់ថាឲ្យខាន |

ខ ដាក់ដើង ម ពីបុរាណ ក្មេងតូចប៉ុន្មានស្គាល់ខ្ជាខ្មា។
ជាតិរាស្ត្រចាស់ក្មេងកុំចិត្តខ្ជាំង គួរខ្វាសបារាំងអ្នកពជការ
ដើមហេតុអំពីព្រះករុណា ឲ្យសាងសាលាប្រែបាលី។
ទ្រង់ចាំទំនៀមពីបុរាណ ហើយបានជំនុំព្រមកុង្សីយ
បំណាច់ធ្វើស្តេចគ្រងផែនដី ទិសទាំងប្រាំបីរំពៃគ្រប់។
ព្រះកាយពលមិនរវល់រែក ព្រះទ័យរំលែកទាំងថ្ងៃយប់
ចូលទែនបន្ទំទីបន្ទប់ បន្ទូលមិនឈប់រាល់វេលា។
មេត្តាប្រោសប្រាណអ្នកមានស័ក្តិ ប្រទានលុយកាក់គ្រប់ភ្នាក់ងារ
ទ្រង់ត្រួតស្ត្រីស្នំស្រីង្គារ ក្រែងគ្រុនរងារមិនបានសុខ។
ព្រះទ័យមេត្តាសព្វមនុស្សសត្វ សោយរាជសម្បត្តិសំបើមស្តុក
ព្រះកាយប្រកបគង់ស្រណុក ព្រះទ័យរិតក្តជាធម្មតា។
មួយព្រួយនឹងឱបព្រះនគរ ពីរព្រួយនឹងពព្រះសាសនា
បីត្រួសលោកសង្ឃកាន់សិក្ខា សង្រួមកិរិយាមិនបរិសុទ្ធ។
នឿយណាស់ព្រះនេត្រព្រះកាណ៌ា ព្រះឱស្ឋត្រួតត្រាច្រើនបំផុត
ដាស់តឿនបំភ័យពួកកុលបុត្រ ឲ្យប្រុងលំអុតសង្រួមកាយ។
បានចេញប្រកាសដាក់ប្រាកដ ប្រគេនគ្រប់វត្តនោះជិតឆ្ងាយ
លោកសង្ឃមិនត្រូវស្រើបសប្បាយ អស់ល្បែងទាំងលាយគ្រប់ចំពូក។
មិនត្រូវចំពោះស្តាប់តន្ត្រី កុំបីមើលរាំវានាំក្លូក
កុំដើរភ្លើៗមើលអុំទូក អ្នកបួសធ្វើលោកមិនត្រូវការ។
បើមានត្រូវកិច្ចដើរយប់ថ្ងៃ សង្ឃបងនិស្ស័យចាស់វស្សា
កុំដើរទឹមស្នាទៅណាៗ អ្នកចេះសិក្ខាគេទាស់ភ្នែក។

លោកនេនកុំសុំលុយចិនចាយ
បិណ្ឌបាតតែបាយម្នាក់១វែក។
គ្រឿងម្ហូបចំណីបាសកចែក
កុំស្ពាយពុនវែកវាថោកវិក។
របស់បាសកគេប្រគេន
ប្រគល់លោកនេនបានលោកភិក្ខុ
ចិញ្ចឹមជីវិតនិងបាយទឹក
បិណ្ឌបាតតែព្រឹកយប់សូត្ររៀន។
លោកណាត្រឹមត្រូវមិនសូវខុស
សៀមស្ងាត់ទៅចុះកុំអន់អៀន
លោកណាមិនចេះកុំវេះវៀន
ពាក្យប្រៀនប្រដៅឲ្យផ្ដើលភ្ញាក់។
ពីព្រោះព្រះអង្គបានផ្ដាំផ្ញើ
វិន័យស្ថិតលើស្ដេចមហាចក្រ
ព្រះមហាចមពង្សទ្រង់ជំពាក់
ចំពោះធុរៈនឹងសាសនា។
ពីត្រឹមនោះរៀងដរាបមក
ដល់ស្រុកគោកធ្លកមានសាវតារ
ប៉ុន្មានពាជ្យហើយមិនដឹងថា
ដល់មកករុណាយើងសព្វថ្ងៃ។
ហេតុនេះលោកសង្ឃប្រុងពិនិត្យ
សៀកៅស្ទឹកវិតមានរាល់ដៃ
ផ្ទៀងមើលសិបផ្លូកវិនិច្ឆ័យ
បើនៅសង្ស័យឲ្យសិក្សា។
លោកសង្ឃចាស់ខ្ទីគប្បីស្ដាប់
ឈ្មោះច្បាប់គន្ធងព្រះពុទ្ធដិកា
បង្គំថ្វាយដល់ព្រះករុណា
សូមទ្រង់មេត្តាជ្រាបព្រះទ័យ។
ក្រែងជួបប្រទះពាក្យផ្ដាំផ្គង
ពុំត្រូវទំនងក្រិត្យវិន័យ
សូមទានសន្ដោសអត់ទោសពៃ
ក្រួញក្រាបសិរសីក្រោមព្រះបាទ។
ព្រះសង្ឃទាំងអស់ទោះតូចធំ
អភ័យទោសខ្ញុំសូមអនុញ្ញាត
ពាក្យខ្ញុំមិនមានពោលប្រមាថ
សង្ឃជាល្អស្អាតខ្ញុំមិនថា។
ខ្ញុំពោលតែលោកធ្វើអាក្រក់
បើខ្ញុំកុហកខូចមុសា
ហេតុនោះខ្ញុំសូមបវារណា
និដ្ឋិតាសង្ខេបតែប៉ុណ្ណោះ។
ក្មេងណាប្រាថ្នាបួសធ្វើសង្ឃ
ឲ្យស្វែងតំរង់រៀនតំរេះ

| | |
|---|---|
| ឲ្យមើលតំរាប់លោកអ្នកចេះ | កុំដេកតែអេះតិះដៀលគ្នា។ |
| អ្នកម្ដាយឪពុកឲ្យឈ្មោះអ៊ូ | ពូជពង្សអំបូរខ្មែរអ្នកជា |
| អាពុកឈ្មោះ អ៊ុកមានស័ក្តិងារ | ចៅពញាជម្មជាពធ្វើមេស្រុក។ |
| ក្នុងខែត្រភ្នំពេញឃុំកំបូល | ជាប់ផៅត្រកូលម្ចាស់អង្គប៉ុក |
| អាពុកអ្នកម្ដាយឈ្មោះពញាម៉ុក | គាត់ធ្វើមេស្រុកឃុំស្ពានថ្ម។ |
| អ្នកម្ដាយអាពុកបងប្អូនជិត | ជីទួតមួយពិតពូជចិត្តល្អ |
| ដូនតាផ្សំផ្គុំជាតំណ | បង្កកើតខ្ញុំទូលបង្គំ។ |
| បង្កើតពីដើមគំនិត | ភ័យភិតខ្លាចបាបចង់បានបុណ្យ |
| បានបែកចែងច្បាប់ប្រាប់មហាជន | បួនច្បាប់ពីមុនជូនរាជការ។ |
| បោះពុម្ពសៀវភៅចែកសព្វសាយ | បណ្ណាល័យចាត់ថ្វាយព្រះករុណា |
| មិនបានថ្វាយផ្ទាល់ដល់ហត្ថា | សូមទ្រង់មេត្តាប្រោសប្រណី |
| ឱនកាយប្រណម្យសូមអនុញ្ញាត | ក្រាបក្រោមព្រះបាទព្រះបារមី |
| ចែងច្បាប់បរមត្ថអត្ថបាលី | សេចក្តីចែងចប់ម្ល៉េះហើយហោង។ |

រៀបចំចងក្រងដោយ

កម្មវិធីស្រាវជ្រាវ និងស្វែងយល់អំពីច្បាប់

www.lorkremlaw.wordpress.com